

# ២០២០

# របាយការណ៍ប្រចាំឆ្នាំ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី

## SAHAKA MICROFINANCE INSTITUTION PLC

023 967 779 , 061 500 979 , 093 500 979 | info@sahakamfi.com | www.sahakamfi.com

ផ្ទះលេខ ២០៦ អឺ០អឺ១, ផ្លូវ ១៥៥, ក្រុមទី៥, ភូមិ១, សង្កាត់ ទួលទំពូងមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ

# មាតិកា


របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល ........ ០១
យើងជានរណា ........ ០៣
ទស្សនវិស័យ បេសកកម្ម ........ ០៤
លទ្ធផលប្រតិបត្តិការសង្ខេប ........ ០៥
លទ្ធផលហិរញ្ញវត្ថុសង្ខេប ........ ០៦
សូចនាករលទ្ធផលហិរញ្ញវត្ថុ ........ ០៧
រចនាសម្ព័ន្ធ ........ ០៨
សមាជិកក្រុមប្រឹក្សាភិបាល ........ ០៩
សមាសភាពគណៈគ្រប់គ្រង ........ ១០
ការគ្រប់គ្រងហានិភ័យ ........ ១២
ការត្រួតពិនិត្យផ្ទៃក្នុង ........ ១៣
គណៈកម្មការនៃគណៈគ្រប់គ្រង ........ ១៤
ផលិតផលរបស់យើង ........ ១៥
អតិថិជនគោលដៅរបស់យើង ........ ១៦
ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង ........ ១៧
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ១៨
របាយការណ៍របស់សវនករឯករាជ្យ ........ ២១
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ ២៤
របាយការណ៍ចំណូលលម្អិត ........ ២៥
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ........ ២៦
របាយការណ៍លំហូរសាច់ប្រាក់ ........ ២៧
កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ........ ២៨



## លោក បុល ខ៉ាន់ឡៀត
## ប្រធានក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ

ជំនួសឲ្យក្រុមប្រឹក្សាភិបាល និងគណៈគ្រប់ គ្រងប្រចាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ទាំងអស់ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ ២០២០ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្ម ប្រចាំឆ្នាំ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ទៅកាន់ ភាគទុនិក និង ភាគីពាក់ព័ន្ធរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី។

### គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី

២០២០ គឺជាឆ្នាំដែលយើងបានផ្តោតសំខាន់លើការផ្លាស់ប្តូរជាវិជ្ជមាន។ វាគឺជាចំណុចមួយដ៏ល្អប្រសើររបស់យើង ក្នុងដំណាក់កាលនៃការប្រកួតប្រជែងដ៏ ខ្លាំងក្លាក្នុង ការប្រយុទ្ធប្រឆាំងនិងការរីករាលដាលនៃមេរោគ Covid-19 ការពង្រីកតំបន់ប្រតិបត្តិការជាមួយនឹងការរៀបចំកំណែទម្រង់រចនាសម្ព័ន្ធដ៏សំខាន់របស់ស្ថាប័ន ប្រកបដោយប្រសិទ្ធភាព ។

ក្នុងឆ្នាំ២០២០ នេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី បានបន្តអនុវត្តគោលដៅចម្បង របស់ខ្លួនដើម្បីក្លាយជាស្ថាប័នដែលឈានមុខ និងអាចជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជន សេដ្ឋកិច្ច និងសង្គមនៃប្រទេសកម្ពុជាដោយបណ្តុះបណ្តាលធនធានមនុស្សតាមរយៈការអប់រំ និងសេដ្ឋកិច្ច ដោយរក្សាកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន ។ លើសពីនេះទៅទៀតស្ថាប័នបានចូលរួមវិភាគទានតាមរយៈសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជាដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគ Covid-19 និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដោយអនុគ្រោះក្នុងការគិតពិន័យដែលអតិថិជនមួយចំនួនមានការយឺតយ៉ាវក្នុងការបង់សងត្រលប់ក៏ដូចជាអនុញ្ញាតតាមការស្នើសុំរបស់អតិថិជនក្នុងការធ្វើឥណទានរៀបចំឡើងវិញក្នុងកំឡុងពេល នៃការរីករាលដាលយ៉ាងខ្លាំងខ្លានៃមេរោគ Covid-19 នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ការរីកចម្រើនវិស័យហិរញ្ញវត្ថុ

ដោយសារតែព្រះរាជាណាចក្រកម្ពុជាជ្រកក្រោមដំបូលសន្តិភាព និង ស្ថេរភាពនៃការរីកចម្រើននៃសេដ្ឋកិច្ចពីមួយឆ្នាំទៅមួយឆ្នាំ និងការពង្រីកខ្លួនជាច្រើននៃស្ថាប័នហិរញ្ញវត្ថុ ដែលបច្ចុប្បន្ននេះយើងឃើញថា ធនាគារពាណិជ្ជ មានចំនួនរហូតទៅដល់ ៤៨ ធនាគារឯកទេសមានចំនួន ១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៧៥ និងក្រុមហ៊ុនភតិសន្យា មានចំនួន ១៥។

### អភិបាលកិច្ច

ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងមានភារកិច្ចទទួលខុសត្រូវធានាឲ្យបាននូវរាល់ប្រតិបត្តិការរបស់គ្រឹះស្ថានទាំងមូល គឺអនុវត្តស្របតាមច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដែលត្រូវបានយកចិត្ត

ទុកដាក់យ៉ាងខ្ជាប់ខ្ជួន។ ដោយយោងលើតួនាទី និងភារកិច្ចក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំយ៉ាងហោចណាស់ម្តងយ៉ាងទៀងទាត់ជារៀងរាល់ឆ្នាំ។ ក្នុងកិច្ចប្រជុំនេះ គឺពិនិត្យមើលការអនុវត្តរបស់ថ្នាក់គ្រប់គ្រង និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើប្រតិបត្តិការរបស់គ្រឹះស្ថានទាំងមូល ។

## ទស្សនវិស័យឆ្នាំ ២០២១

យោងតាមស្ថានភាពជាក់ស្តែងក្នុងប្រទេសកម្ពុជា កំពុងតែជួបប្រទះការរីករាលដាលមេរោគ Covid-19 ដែលជាហេតុធ្វើអោយការរីកចម្រើនផ្នែកសេដ្ឋកិច្ចមានការធ្លាក់ចុះ និងធ្វើអោយប្រជាជនបាត់បង់ការងារ បាត់បង់ប្រាក់ចំណូល ដោយវិស័យធំៗជាច្រើនស្ទើតែមិនមានសកម្មភាពទាល់តែសោះ ដូចជាទេសចរណ៍ សេវាកម្ម និង បដិសណ្ឋារកិច្ច ការកាត់បន្ថយនូវការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់ វិស័យវាយនភណ្ឌ វីស័យដឹកជញ្ជូន ។ ដោយកត្តាទាំងនេះហើយដែលធ្វើអោយការរាំងស្ទះជាខ្លាំងដល់កំណើនសេដ្ឋកិច្ចជាតិ ដែលធ្វើអោយរាជរដ្ឋាភិបាលមានការលំបាកជាខ្លាំងក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ និងការស្តាសេដ្ឋកិច្ចជាតិឡើងវិញប្រកដោយនិរន្តរភាព ។ ក្នុងនាមយើងជាស្ថាប័នហិរញ្ញវត្ថុមួយដែលមានទស្សនវិស័យ ក្នុងការជួយប្រជាជនកម្ពុជាតាមរយៈការបង្កើនជីវភាពរស់នៅរបស់ប្រជាជន សេដ្ឋកិច្ចសង្គម ដោយបណ្តុះបណ្តាលធនធានមនុស្សតាមរយៈការអប់រំ និងសេដ្ឋកិច្ច នៅតែមានការប្តេជ្ញាចិត្តក្នុងការថែរក្សា និងផ្តល់ឥណទានប្រកបដោយគុណភាព និងប្រសិទ្ធភាពជូនដល់ប្រជាជនដើម្បីជួយពួកគាត់ក្នុងការបង្កើនប្រាក់ចំណូល ក៏ដូចជាជួយរាជរដ្ឋាភិបាល ក្នុងការស្តារសេដ្ឋកិច្ចជាតិឡើងវិញប្រកបដោយនិរន្តរភាព ។

## ការទទួលស្គាល់

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគីពាក់ព័ន្ធទាំងអស់ ទាំងអតិថិជន អ្នកវិនិយោគ និង ដៃគូហិរញ្ញវត្ថុ ទាំងក្នុងស្រុក និងក្រៅស្រុក សម្រាប់ការជឿជាក់ ការសហការ និងការគាំទ្រដល់ការរីកចម្រើនក្នុងឆ្នាំកន្លងមក។ ម្តងទៀតនេះ ខ្ញុំបាទក៏សូមអរគុណចំពោះក្រុមការងារ ក្នុងក្រុមប្រឹក្សាភិបាលសម្រាប់ការផ្តល់ជាអនុសាសន៍ និងការណែនាំ និងក្រុមការងារដែលស្ថិតក្នុងថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់នៅទីនេះ ដែលបានដឹកនាំប្រកបដោយសមត្ថភាពនិងការតាំងចិត្ត សម្រាប់ការងារដ៏ប្រសើរកន្លងមក។យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណ ដល់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា និយ័តករ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលតែងតែជួយគាំទ្រ និងប្រឹងប្រែងអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា អោយរីកចម្រើនប្រកបដោយនិរន្តរភាព ។ យើងខ្ញុំសូមធានាចំពោះអតិថិជន និងភាទុនិកទាំងអស់ឲ្យបានជ្រាបថា នៅក្នុងឆ្នាំ ២០២១ នេះយើងខ្ញុំនឹងបន្តការយកចិត្តទុកដាក់ និងផ្តល់ឥណទានដល់ប្រជាជនប្រកបដោយគុណភាព និងប្រសិទ្ធភាពនឹងទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគ Covid-19 យ៉ាងខ្លាំងខ្លាបំផុតក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុ។




បុល វ៉ាន់នៀត
ប្រធានក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ
១៥ មិថុនា ២០២១

## យើងជានរណា?

សហការ ត្រូវបានបង្កើតឡើងនៅក្នុងខែធ្នូ ឆ្នាំ២០១៥ ដោយវិនិយោគិន ២រូប ជាជនជាតិខ្មែរ និងជនជាតិជប៉ុន។ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី** ត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងទទួលបានអាជ្ញាប័ណ្ណដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា នៅក្នុងខែ មេសា ឆ្នាំ ២០១៦ និងចាប់ផ្តើម ប្រតិបត្តិការអាជីវកម្ម នៅក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់នូវ សេវាកម្មហិរញ្ញវត្ថុ តាមរយៈការផ្តល់កម្ចីទៅកាន់អតិថិជន។

រយៈពេលជាង ៥ ឆ្នាំ នៃការប្រតិបត្តិអាជីវកម្ម **សហការ** បានផ្តល់សេវាកម្មជូនអតិថិជនជាច្រើន ទាំងក្នុងទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តនានាមួយចំនួន។

ចាប់តាំងពីទទួលបានអាជ្ញាប័ណ្ណមក យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការចូលរួមលើកកម្ពស់ជីវភាពប្រជាជន និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងតាមរយៈការផ្តល់កម្ចីប្រកបដោយគុណភាព និងប្រសិទ្ធភាព។ លើសពីនេះទៀតស្ថាប័នយើងខ្ញុំបានគោរពនិងប្រតិបត្តិតាមយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ និងបញ្ញត្តិផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា និងនិយ័តករដ៏ទៃទៀតជាពិសេសតែងតែប្រតិបត្តិតាមជានិច្ចនូវសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុស្របទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងគោរពទៅតាមបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ពីឆ្នាំ២០១៩ មក សហការ បានអនុវត្តនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ កម្ពុជា អន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SME) ប្រកបដោយភាពត្រឹមត្រូវនិងពេញលេញ ដោយឆ្លងកាត់ការធ្វើសវនកម្មឯករាជ្យយ៉ាងត្រឹមត្រូវ។

**ទីស្នាក់ការកណ្តាល:**
ផ្ទះលេខ ២០៦អឺ០អឺ១ ផ្លូវ ១៥៥ កែងផ្លូវ ៤៧០ សង្កាត់ទួលទំពូងទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ទូរស័ព្ទ ៖ +855 (0)23 967 779
អ៊ីម៉ែល ៖ sahakamfi@sahakamfi.com
វេបសាយ ៖ www.sahakamfi.com
ផ្នែកបម្រើអតិថិជន ៖ +855 (0)61 500 979 / +855 (0)93 500 979
អ៊ីម៉ែល ៖ info@sahakamfi.com



# ទស្សនវិស័យ បេសកកម្ម

## ទស្សនវិស័យ

ដើម្បីក្លាយជាស្ថាប័នដែលឈានមុខ ដែលអាចជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជន សេដ្ឋកិច្ច និងសង្គម នៃប្រទេសកម្ពុជា ដោយបណ្តុះបណ្តាល ធនធានមនុស្សតាមរយៈការអប់រំ និងសេដ្ឋកិច្ច ដោយរក្សាកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន គឺ (ធអសក)។

## បេសកកម្ម

គោលគំនិតអាជីវកម្មរបស់ពួកយើង គឺផ្តល់ជាសេវាកម្មហិរញ្ញវត្ថុ ជាមួយអាត្រាការប្រាក់សមរម្យដែលប្រជាជនអាចមានលទ្ធភាពប្រើប្រាស់សេវាកម្មរបស់ពួកយើងដើម្បីបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅរបស់ប្រជាជន។



# លទ្ធផលប្រតិបត្តិការសង្ខេប

## ផលបត្រឥណទាន

| គិតជាដុល្លារអាមេរិក | ២០១៨ | ២០១៩ | ២០២០ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា(%) |
|---|---|---|---|---|---|
| ឥណទានសុទ្ធ | ៥,៣១៨,១៤៤ | ៣,៣៣៦,៨៨៣ | ៥,២៥៩,៦៩៥ | ១,៩២២,៨១២ | ៥៦,៦២% |
| ឥណទានសុទ្ធសរុប | ៥,៣១៨,១៤៤ | ៣,៣៣៦,៨៨៣ | ៥,២៥៩,៦៩៥ | ១,៩២២,៨១២ | ៥៦,៦២% |

## ចំនួនអតិថិជនទទួលកម្ចី

| គិតជាដុល្លារអាមេរិក | ២០១៨ | ២០១៩ | ២០២០ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា(%) |
|---|---|---|---|---|---|
| ចំនួនអតិថិជនស្ត្រី | ១៨៩ | ៣៨១ | ១០០ | (២៨១) | (៧៣,៧៥%) |
| ចំនួនអតិថិជនបុរស | ៤០២ | ៣៦០ | ២៩០ | (៧០) | (១៩,៤៤%) |
| ចំនួនអតិថិជនសរុប | ៥៩១ | ៧៤១ | ៣៩០ | (៣៥១) | (៤៧,៣៧%) |

## ឥណទានបានបញ្ចេញ

| គិតជាដុល្លារអាមេរិក | ២០១៨ | ២០១៩ | ២០២០ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា(%) |
|---|---|---|---|---|---|
| ឥណទានបានបញ្ចេញ (ដុល្លារអាមេរិក) | ២,៩៧០,៣៤៦ | ២,៦៥៥,១៧២ | ៤,២៨៩,៥៨៧ | ១,៦៣៤,៤១៥ | ៦១,៥៦% |
| ចំនួនអតិថិជន | ៤០២ | ៣៦០ | ២៩០ | (៧០) | (៥៨,៩២%) |



# លទ្ធផលហិរញ្ញវត្ថុសង្ខេប

## របាយការណ៍ហិរញ្ញវត្ថុសង្ខេប (ដុល្លារអាមេរិក)

### ទ្រព្យសកម្ម

| កាលបរិច្ឆេទ | ២០១៨ | ២០១៩-CIFRS | ២០២០- CIFRS |
|---|---:|---:|---:|
| ឥណទានផ្តល់ដល់អតិថិជន (សុទ្ធ) | ៥,២៦៤,៩០០ | ៣,៣៣៦,៨៨៣ | ៥,២៥៩,៦៩៥ |
| ទ្រព្យសកម្មសរុប | ៧,០៥៨,១៣៦ | ៤,១៧១,៦៦៣ | ៥,៩៤៦,០៦៧ |

### បំណុល និងមូលធន

| កាលបរិច្ឆេទ | ២០១៨ | ២០១៩-CIFRS | ២០២០- CIFRS |
|---|---:|---:|---:|
| បំណុលសរុប | ៥,៨១៧,១៣៧ | ៣,៧៧៩,៣៥៦ | ៤,៦១៩,៤៩៤ |
| មូលធនសរុប | ១,២៤០,៩៩៩ | ៣៩២,៣០៧ | ១,៣២៦,៥៧៣ |

### ចំណូល និងចំណាយ

| កាលបរិច្ឆេទ | ២០១៨ | ២០១៩-CIFRS | ២០២០- CIFRS |
|---|---:|---:|---:|
| ចំណូលការប្រាក់ | ៨៧៨,៥៤៤ | ៧៥០,៥៨២ | ៧៣៥,៥៩៥ |
| ចំណាយការប្រាក់ | (៣៨៧,៣៤៣) | (៣៨៥,៨៧៤) | (១៨៥,១៤៧) |
| ពន្ធលើប្រាក់ចំណេញ | (៩,៧២៦) | (៨,៣២០) | (១០,៤៦៥) |
| ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ | (៤២៧,៦៧២) | (១,៣៩៨,៩១០) | (៦៥,៧៣៤) |



# សូចនាករលទ្ធផលហិរញ្ញវត្ថុ

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| **ឥណទានផ្តល់ដល់អតិថិជន ( សុទ្ធ )** | | | |
| អនុបាតចំណាយប្រតិបត្តិការ | ១១,៣៨% | ១៨,៣២% | ១៤,១៣% |
| ទំហំឥណទានជាមធ្យម (ដុល្លារអាមេរិក) | ៩,៥១៣ | ៥,២១៨ | ១៤,៤១៨ |
| ចំនួនឥណទានក្នុងមន្រ្តីឥណទានម្នាក់ (ដុល្លារអាមេរិក) | ៥៨៤,៩៨៩ | ៤៧៦,៦៩៨ | ៣៥០,៦៤៦ |
| ចំនួនអតិថិជនក្នុងមន្រ្តីឥណទានម្នាក់ | ៥៩ | ៧៣ | ២៦ |
| ចំនួនអតិថិជនក្នុងបុគ្គលិកម្នាក់ | ១៧ | ២០ | ៩ |
| **តំបន់ប្រតិបត្តិការ** | | | |
| ខេត្ត/រាជធានី | ១៦ | ២៤ | ១១ |
| ស្រុក/ខណ្ឌ | ៥៤ | ១១៩ | ៤០ |
| ឃុំ/សង្កាត់ | ១៣៥ | ៣៣១ | ១៣២ |
| ភូមិ | ២២៤ | ៤៦០ | ២៣៣ |



# រចនាសម្ព័ន្ធ


ម្ចាស់ភាគហ៊ុន
គណៈកម្មការសវនកម្មឯករាជ្យ
គណៈកម្មការតែងតាំង និងកម្រៃការ
ក្រុមប្រឹក្សាភិបាល
គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
ប្រធាននាយកប្រតិបត្តិ
គណៈកម្មការសវនកម្ម
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
គណៈកម្មការឥណទាន
គណៈកម្មការវិន័យ និងបណ្តឹង
គណៈកម្មការអភិវឌ្ឍន៍ យុទ្ធសាស្ត្រ និងគោលការណ៍
ប្រធាននាយកប្រតិបត្តិការ
ប្រធាននាយកហិរញ្ញវត្ថុ
នាយកដ្ឋានឥណទាន
ផ្នែកផ្តល់កម្ចី
ផ្នែកគ្រប់គ្រងគុណភាពផលប័ត្រឥណទាន
នាយកដ្ឋានប្រតិបត្តិការ
ផ្នែករដ្ឋបាល
ផ្នែកទីផ្សារ
ផ្នែកបេឡា
នាយកដ្ឋានព័ត៌មានវិទ្យា
ផ្នែកសុវត្ថិភាពបណ្តាញព័ត៌មានវិទ្យា
ផ្នែកអភិវឌ្ឍន៍ប្រព័ន្ធធនាគារ
នាយកដ្ឋានហិរញ្ញវត្ថុ
ផ្នែកបៀវត្ស និងគណនេយ្យ
ផ្នែករតនាគារ និងរបាយការណ៍
ផ្នែកធនធានមនុស្ស

# សមាជិកក្រុមប្រឹក្សាភិបាល



### លោក បុល វ៉ាន់នៀត
### ប្រធានក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ

លោក បុល វ៉ាន់នៀត ជានាយកប្រតិបត្តិ ប្រចាំគ្រឹះស្ថាន។ បន្ទាប់ពីបានបញ្ចប់ថ្នាក់ បរិញ្ញាប័ត្រភាសារជប៉ុន ខាងផ្នែកអប់រំពីវិទ្យាស្ថានភាសាបរទេសនិង បានបញ្ចប់ថ្នាក់ទស្សនៈកិច្ចសិក្សាពីប្រទេសជប៉ុន លោកបានចូលបម្រើការងារនៅក្នុងធនាគារ Bank of Tokyo-Mitsubishi UFJ Ltd (BTMU)។ លោកក៏ ជានាយកប្រតិបត្តិ ប្រចាំក្រុមហ៊ុន នៀតអេដ្យូខេសិនណាល អ៊ីនហ្វមេសិន សិនធ័រ ខូអិលធីឌី និងជានាយកប្រតិបត្តិ ប្រចាំក្រុមហ៊ុន នីខេម ខូអិលធីឌី ផងដែរ។



### លោក តាកាហ៊ីរ៉ុ យ៉ាម៉ាស៊ីតា
### សមាជិកក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក តាកាហ៊ីរ៉ុ យ៉ាម៉ាស៊ីតា ជានាយកហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន ហើយគាត់ក៏ជា នាយកហិរញ្ញវត្ថុ ប្រចាំក្រុមហ៊ុន នៀតអេដ្យូខេសិនណាល អ៊ីនហ្វមេសិន សិនធ័រ ខូអិលធីឌី និងក្រុមហ៊ុន នីខេម ខូអិលធីឌី ផងដែរ។ បច្ចុប្បន្ននេះ លោកក៏មានតួនាទីជានាយកប្រតិបត្តិ ប្រចាំក្រុមហ៊ុន ស៊ីភីអូឌី ប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេសសឹង្ហបុរីផងដែរ។លោក តាកាហ៊ីរ៉ុ មានបទពិសោធន៍ជាង ១៦ឆ្នាំក្នុងវិស័យសេវាកម្មប្រឹក្សាយោបល់ខាងផ្នែក ហិរញ្ញវត្ថុ។



### លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអ៊ីឈិ
### ក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអ៊ីឈិ ជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យប្រចាំគ្រឹះស្ថាន។ លោកក៏ជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន TM Pte. Ltd ដែលជាក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិឯកជន និងវិនិយោគ ហើយក៏ជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន Miyauchi Electric Engineering Co., LTD នៅក្នុងប្រទេស ជប៉ុនផងដែរ។ លោក តូស៊ីហ៊ីរ៉ូ មានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការគ្រប់គ្រងអាជីវកម្ម និង ហិរញ្ញវត្ថុនៅក្នុងប្រទេសជប៉ុន។

# សមាសភាពគណៈគ្រប់គ្រង



### លោក ស៊ុម ស៊ីណាត
### នាយកប្រតិបត្តិការ

លោក ស៊ុម ស៊ីណាត ជានាយកប្រតិបត្តិការ ប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម នៅក្នុងឆ្នាំ ២០០៧ បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងអាជីវកម្ម និង បរិញ្ញាប័ត្ររងផ្នែកគណនេយ្យ នៅក្នុងឆ្នាំ ២០០៥។ លោក មានបទពិសោធន៍ជាង១៧ ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងទទួលប្រាក់បញ្ញើរ និង មិនទទួលប្រាក់បញ្ញើរ នៅក្នុងប្រទេសកម្ពុជា។



### លោក ប៉ុល វុទ្ធីរីថ
### ប្រធានគ្រប់គ្រងឥណទាន

លោក ប៉ុល វុទ្ធីរីថ ជាប្រធានគ្រប់គ្រងឥណទានប្រចាំគ្រឹះស្ថាន។ លោកកំពុងបន្តយកបរិញ្ញាប័ត្រផ្នែកច្បាប់ បន្ទាប់ពីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញគណនេយ្យ ក្នុងឆ្នាំ ២០០៦។ លោក វុទ្ធីរីថ មានបទពិសោធន៍ជាង ១៥ ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើរ និងធនាគា នៅក្នុងប្រទេសកម្ពុជា។



### លោក ដុំ ឌី
### ប្រធានគ្រប់គ្រងហិរញ្ញវត្ថុស្ដីទី

លោក ដុំ ឌី ជាប្រធានគ្រប់គ្រងហិរញ្ញវត្ថុស្ដីទីប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញគណនេយ្យ ក្នុងឆ្នាំ ២០១៣។លោក ដុំ ឌី មានបទពិសោធន៍ជាង ៧ ឆ្នាំ ខាងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ពន្ធដារក្នុងវិស័យហិរញ្ញវត្ថុជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើរធនាគា និងក្រុមហ៊ុនផ្ទេរប្រាក់ក្នុងស្រុក នៅក្នុងប្រទេសកម្ពុជា។

## អ្នកស្រី ភឿក សម្ភស្ស
## ប្រធានគ្រប់គ្រង ផ្នែកធនធានមនុស្ស និងរដ្ឋបាល



អ្នកស្រី ភឿក សម្ភស្ស ជាប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស និងរដ្ឋបាល។ អ្នកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ជំនាញគណនេយ្យក្នុងឆ្នាំ ២០១១។ អ្នកស្រី មានបទពិសោធន៍ជាង ១០ ឆ្នាំក្នុងជំនាញជាគណនេយ្យករ និងរដ្ឋបាល ជាមួយនឹងវិស័យឯកជនជាច្រើនដូចជា ក្រុមហ៊ុនលក់ទំនិញ សណ្ឋាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## លោក ជី ឡុងហេង
## ប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុង



លោក ជី ឡុងហេង ជាប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុងប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុនៅក្នុងឆ្នាំ ២០១៩ និង ថ្នាក់ បរិញ្ញាប័ត្រផ្នែកគណនេយ្យក្នុងឆ្នាំ ២០១២។ លោកមានបទពិសោធន៍ជាង ៧ ឆ្នាំក្នុងផ្នែកហិរញ្ញវត្ថុ គណនេយ្យ និង សវនកម្ម ជាមួយនឹង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងទទួលប្រាក់បញ្ញើរ និងមិនទទួលប្រាក់បញ្ញើរ និងក្រុមហ៊ុនភតិសន្យានៅក្នុងប្រទេសកម្ពុជា។

## លោក នៅ វិច្ឆិកា
## ប្រធានគ្រប់គ្រង ផ្នែកគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម



លោក នៅ វិច្ឆិកា ជាប្រធានគ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញ សេដ្ឋកិច្ច ក្នុងឆ្នាំ២០១០ និងថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងទូទៅក្នុងឆ្នាំ ២០១៥។ លោកមានបទពិសោធន៍ជាង ១០ ឆ្នាំ ជាអ្នកសម្របសម្រួលផ្នែកទីផ្សាររយៈពេល៤ឆ្នាំ ហើយបានផ្លាស់ប្តូរមកវិស័យធនាគារ និង ហិរញ្ញវត្ថុចាប់តាំងពីឆ្នាំ ២០១៤។

## ការគ្រប់គ្រងហានិភ័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី បានបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យបានយ៉ាងល្អប្រសើ ដើម្បីធានាកម្រិតហានិភ័យដែលអាចកើតមានឡើងទាបបំផុត។រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យនេះជួយសម្របសម្រួល ក្នុងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ទៅលើការប្រមើលមើល និងការប្រតិបត្តិការគ្រប់គ្រងហានិភ័យ និងដំណើរការនៃការត្រួតពិនិត្យហានិភ័យ។
នាយកដ្ឋានគ្រប់គ្រងហានិភ័យ មានមុខងារឯករាជ្យនិងដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហានិភ័យ និងរាយការណ៍ដោយផ្ទាល់ជូនដល់ក្រុមប្រឹក្សាភិបាល។

## ហានិភ័យឥណទាន

តួនាទីសំខាន់ គឺការទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងហានិភ័យឥណទាន ការកំណត់លក្ខខណ្ឌសម្រាប់ការវិនិច្ឆ័យលើការអនុម័តឥណទាន ការតាមដាន និងការគ្រប់គ្រងហានិភ័យ ការចាត់ថ្នាក់ហានិភ័យឥណទាន ការវិភាគហានិភ័យលើផលបត្រឥណទានដោយមានការផ្តល់ជាអនុសាសន៍ និងការចុះទៅត្រួតពិនិត្យឥណទានដោយផ្ទាល់ដោយឯករាជ្យ។

## ហានិភ័យប្រតិបត្តិការ

សហការ តែងតែអនុវត្តជាប្រចាំទៅលើការវាយតម្លៃលើហានិភ័យ និងការគ្រប់គ្រង ការតាមដានសូចនាករហានិភ័យសំខាន់ៗនិងធ្វើតេស្តជាប្រចាំទៅលើផែនការនិរន្តរភាពអាជីវកម្ម ពិសេសក្នុងស្ថានភាពការរីករាលដាលនៃកូវីដ១៩។ ការដាក់ឱ្យប្រើប្រាស់ផលិតផលថ្មីៗ និងការកែសម្រួលផលិតផលសេវាកម្មដែលមានស្រាប់ ឬការកែសម្រួលដំណើរការ គឺតម្រូវឱ្យធ្វើការវាយតម្លៃហានិភ័យឱ្យបានល្អិតល្អន់ដើម្បីការពារនិងកាត់បន្ថយហានិភ័យដែលអាចកើតមានឡើង។

## ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ សំដៅដល់ការខាតបង់ដែលបណ្តាលមកពីតម្លៃ ឬអត្រាដែលអាចកើតមានឡើងនៅក្នុងបញ្ជីជួញដូរ ឬក្នុងបញ្ជីដែលមិនជួញដូរ ដែលមាននៅ ក្នុងតារាងតុល្យការ និងក្រៅតារាងតុល្យការ។ បើទោះបីជាកម្រិតហានិភ័យនេះមានប៉ុណ្ណាក៏ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ប្រឈមតែនឹងហានិភ័យតែមួយប៉ុណ្ណោះ គឺហានិភ័យមិនជួញដូរ ដែលរួមមានអត្រាការប្រាក់។

## ហានិភ័យសាច់ប្រាក់ងាយស្រួល

សហការ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្តល់តែសេវាកម្មឥណទានតែប៉ុណ្ណោះ ដូច្នេះចំពោះហានិភ័យប្រភេទនេះ គឺមិនមានអ្វីប៉ះពាល់ដល់ស្ថាប័នយើងឡើយ។ ដោយសារតែការគ្រប់គ្រងសាច់ប្រាក់បានល្អប្រសើរដូច្នេះស្ថាប័នយើងមិនមានបញ្ហាចំពោះលំហូរសាច់ប្រាក់នោះឡើយ។



## ការត្រួតពិនិត្យផ្ទៃក្នុង

រចនាសម្ព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំធ្វើឱ្យគ្រឹះស្ថានទាំងមូលធានាបាននូវប្រសិទ្ធភាពការងារ និងហានិភ័យដែលអាចកើតមានឡើងចំពោះស្ថាប័នដែលត្រូវមានការចូលរួមពីគ្រប់បុគ្គលិកនិងថ្នាក់គ្រប់គ្រងទាំងអស់។ សវនកម្មផ្ទៃក្នុងរបស់ សហការ ត្រូវទទួលខុសត្រូវក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួមទាំងពិនិត្យមើលការប្រតិបត្តិតាមរបស់ស្ថាប័នទៅនឹងបទបញ្ញត្តិនានាផងដែរ ហើយរាយការណ៍ដោយឯករាជ្យទៅកាន់ប្រធានគណៈកម្មការសវនកម្មនៃក្រុមប្រឹក្សាភិបាល។

សកម្មភាពសវនកម្មផ្ទៃក្នុងមានភាពឯករាជ្យមិនលម្អៀង ក្នុងការធានាអះអាងនិងប្រឹក្សាយោបល់ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យប្រសើឡើងទៅលើប្រតិបត្តិការរបស់ សហការ ទាំងមូល។ សវនកម្មផ្ទៃក្នុងបានរួមចំណែកជួយឱ្យ សហការ សម្រេចផែនការតាមរយៈការផ្តល់នូវវិធីសាស្ត្រវាយតម្លៃ និងវិន័យនិងជួយធ្វើឱ្យប្រសើឡើងលើប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការអភិបាលកិច្ច។

សកម្មភាពសវនកម្មផ្ទៃក្នុងមិនត្រូវបានរារាំងដោយផ្នែកណាមួយនៅក្នុងអង្គភាពឡើយរួមមាន នីតិវិធីធ្វើសវនកម្ម វិសាលភាព ភាពញឹកញាប់ ពេលវេលា ឬការរាយការណ៍ ដើម្បីរក្សាអោយមានឯករាជ្យភាពនិងសុក្រឹតភាពតាមការចាំបាច់។ ដោយសារសកម្មភាពឯករាជ្យទាំងនេះហើយទើបធ្វើឱ្យការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ សហការ ប្រព្រឹត្តទៅបានល្អប្រសើនិងមានប្រសិទ្ធភាព។

សវនករផ្ទៃក្នុង ត្រូវតែមានឯករាជ្យភាពដោយមិនចូលរួមធ្វើប្រតិបត្តិការប្រចាំថ្ងៃ និងត្រូវជៀសវាងការចូលរួមដែលអាចប៉ះពាល់ដល់លទ្ធភាពរបស់ពួកគាត់ក្នុងការផ្តល់សេវាកម្មប្រកបដោយឯករាជ្យភាព និងសុក្រឹតភាព។ សម្រាប់ការធ្វើសវនកម្មផ្ទៃក្នុង សវនករមិនមានតួនាទី ឬសិទ្ធិលើសពីសកម្មភាពត្រួតពិនិត្យ និងការធ្វើសវនកម្មនោះទេ។



## គណៈកម្មការនៃគណៈគ្រប់គ្រង

ដើម្បីឱ្យការគ្រប់គ្រងមានប្រសិទ្ធភាពខ្ពស់ និងធានាដល់ការរីកចម្រើនរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី យើងបានរៀបចំនូវប្រព័ន្ធអភិបាលកិច្ចសម្រាប់អនុវត្ត សម្រេចចិត្ត និងចាត់ចែងការងារគ្រប់គ្រងនៅក្នុងស្ថាប័នទាំងមូល។ ប្រព័ន្ធគ្រប់គ្រងនេះ គ្រឹះស្ថានបានបានរៀបចំ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ។

### គណៈកម្មការតែងតាំងនិងតម្រៃការ

គណៈកម្មការនេះត្រូវបានបង្កើតឡើងដើម្បីកំណត់លក្ខខណ្ឌពាក់ព័ន្ធនឹងការតែងតាំង ឬបញ្ឈប់នាយកគ្រប់គ្រង។ បន្ថែមលើនេះទៀត គណៈកម្មការមានសិទ្ធិក្នុងការកំណត់ និងស្នើ តែងតាំង ឬ បញ្ឈប់នាយកគ្រប់គ្រង ទៅកាន់កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ។

### គណៈកម្មការសវនកម្ម

គណៈកម្មការនេះត្រូវបានបង្កើតឡើងសម្រាប់ការរៀបចំការធ្វើសវនកម្ម និងធានាពីការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ស្ថាប័នទាំងមូលអោយមានប្រសិទ្ធភាពខ្ពស់ ។ លើសពីនេះទៀត គណៈកម្មការមានសិទ្ធិ សម្រេចនិងស្នើ តែងតាំង ឬ បញ្ឈប់សវនករឯករាជ្យ ទៅកាន់កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំផងដែរ។

### គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គណៈកម្មការនេះគឺត្រូវបានបង្កើតឡើងសម្រាប់ធ្វើជាអ្នករៀបចំនូវប្រព័ន្ធគ្រប់គ្រងហានីភ័យ និងគោលការប្រតិបត្តិ ប្រកបដោយប្រសិទ្ធភាព កំហុសឆ្គង និងការប្រតិបត្តិតាមដំណើរការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ។ គណៈកម្មការនេះមានតួនាទីត្រួតពិនិត្យការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃរបស់គ្រឹះស្ថានទាំងមូល។ គណៈកម្មការនេះមានមុខងារឯករាជ្យក្នុងការគ្រប់គ្រងហានិភ័យ និងរាយការណ៍ផ្ទាល់ទៅក្រុមប្រឹក្សាភិបាល។

### គណៈកម្មការឥណទាន

គណៈកម្មការនេះត្រូវបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យ និងទទួលរបាយការណ៍ដែលចាំបាច់ ពីផ្នែកនៃគណៈគ្រប់គ្រងផ្សេងដើម្បីធ្វើការប៉ាន់ស្មាន និងគ្រប់គ្រងហានីភ័យ ឥណទាន។ គណៈកម្មការមានតួនាទីក្នុងការចាត់ចែង និងធ្វើការគ្រប់គ្រងលើប្រសិទ្ធភាព និងប្រតិបត្តិទៅតាមគោលនយោបាយឥណទាន តាមរយៈការត្រួតពិនិត្យលើនីតិវិធី ការទទួលរបាយការណ៍ និងព័ត៌មានផ្សេងៗដែលមានសារៈសំខាន់ រួមមាន ការឲ្យពិន្ទុលើគុណភាពនៃឥណទាន ការត្រួតពិនិត្យលើដំណើរការឥណទាន ការគាំទ្រដល់ការធ្វើសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យ។ គណៈកម្មការក៏មានតួនាទីក្នុងការត្រួតពិនិត្យ សមត្ថភាពការងារ និង គុណភាព នៃឥណទានតាមរយៈការពិនិត្យលើគំរូឥណទានដែលបានជ្រើសរើស និងព័ត៌មានដសមរម្យ រួមបញ្ចូលទាំងការចាត់ថ្នាក់ឥណទាន និងឥណទានមិនដំណើរការ។

### គណៈកម្មការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងគោលការណ៍

គណៈកម្មការនេះត្រូវបានបង្កើតឡើងដើម្បីជជែកពិភាក្សារវាងនាយកដ្ឋាន ឬផ្នែកផ្សេងៗដើម្បីបង្កើតជាផលិតផលសម្រាប់បំពេញតម្រូវការរបស់អតិថិជននិងប្រគួតប្រជែងនៅក្នុងទីផ្សារ។ គណៈកម្មការនេះត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ផ្នែកឥណទានដើម្បីបង្កើតផលិតផលថ្មីដែលអាចយកចំណែកទីផ្សារក្នុងវិស័យហិរញ្ញវត្ថុមួយផ្នែកជារបស់ សហការ។

# ផលិតផលរបស់យើង

## ឥណទានអាជីវកម្ម



ផលិតផលឥណទានអាជីវកម្ម ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនជារូបវន្តបុគ្គលដែលមានបំណងប្រើប្រាស់សម្រាប់ការចាប់ផ្តើមអាជីវកម្ម ការពង្រីកអាជីវកម្ម ដែលការប្រើប្រាស់នេះសមស្របទៅតាមបេសកកម្មរបស់គ្រឹះស្ថានយើងក្នុងការបង្កើនប្រាក់ចំណូល និងជីវភាពប្រជាជន។

## ឥណទានគេហដ្ឋាន



ផលិតផលឥណគេហដ្ឋាន ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនជារូបវន្តបុគ្គលដែលមានបំណងប្រើប្រាស់ក្នុងការទិញគេហ-ដ្ឋានដោយមិនកំណត់លក្ខខណ្ឌ។ អតិថិជនអាចយកទ្រព្យដែលទិញស្រាប់ ឬ ទ្រព្យផ្សេងជំនួសដើម្បីធ្វើជាទ្រព្យបញ្ចាំសម្រាប់ឥណទានប្រភេទនេះ។

## ឥណទានរថយន្ត



ផលិតផលឥណទានរថយន្ត គឺបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជនដែលមានតម្រូវការប្រើប្រាស់រថយន្តផ្ទាល់ខ្លួនឬសម្រាប់គ្រួសារ ដែលគាត់អាចស្នើប្រើប្រាស់ឥណទានប្រភេទនេះបានយ៉ាងងាយស្រួលនិងរហ័សទាន់ចិត្ត។

## ឥណទានការសិក្សា



ផលិតផលឥណទានសិក្សា ត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការដល់អតិថិជនដែលជា សិស្ស និស្សិត ដែលមានបំណងបន្តការសិក្សាប៉ុន្តែមិនមានលទ្ធភាព ដោយសារការចំណាយទៅលើ ថ្លៃសិក្សា សម្ភារៈសិក្សា ដូច្នេះឥណទានប្រភេទនេះគឺតម្រូវការដ៏ពិតប្រាកដសម្រាប់ពួកគាត់ ដើម្បីបន្តក្តីស្រមៃទៅថ្ងៃអនាគត។

## ឥណទានផ្ទាល់ខ្លួន



ផលិតផលឥណទានផ្ទាល់ខ្លួន ត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជន ដែលមានបំណងប្រើប្រាស់សាច់ប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ និងសម្រាប់គោលបំណងផ្ទាល់ខ្លួនជាក់លាក់។ ឥណទានប្រភេទនេះបង្កភាពងាយស្រួលដល់អតិថិជនជាទីបំផុតដោយសារតែវាមានភាពរហ័ស និងរយៈពេលវែងដែលអតិថិជនអាចសងត្រលប់មកវិញដោយប្រសិទ្ធភាព។

## គ្រួសារ



ដោយសារកម្ពុជាមានកំណើនសេដ្ឋកិច្ចជាលំដាប់ជាហេតុធ្វើឱ្យប្រជាជនមានចំណូលកើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈមុខរបរកសិកម្ម ជួញដូរ សេវាកម្ម ដឹកជញ្ជូន។ ចំណូលរបស់គាត់កើនឡើងជាលំដាប់នេះហើយ ដែលអាចឱ្យពួកគាត់មានលទ្ធភាពប្រើប្រាស់ផលិតផលឥណទានរថយន្តរបស់ សហការ ប្រកបដោយទំនុកចិត្តនិងនិរន្តរភាព។

## អតិថិជនគោលដៅរបស់យើង



ការផ្តល់សេវាកម្មហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាព គឺជាចំណុចយ៉ាងសំខាន់ដែលគ្រឹះស្ថានរបស់យើងបានប្រកាន់យកដើម្បីស្របទៅតាមបេសកកម្មរបស់យើង និងអនុវត្តដើម្បីបំពេញតម្រូវការរបស់អតិថិជនដោយផ្តល់ជូនតាមប្រភេទផ្ទាល់ខ្លួន និងអាជីវកម្មខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម។ ជាមួយនឹងអត្រាការប្រាក់ និងតម្លៃសេវាសមរម្យ ដែលអាចឱ្យអតិថិជនធ្វើការសម្រេចចិត្តយ៉ាងងាយស្រួល មុននឹងធ្វើការជ្រើសរើសប្រើប្រាស់ផលិតផលរបស់ សហការ។

## សហគ្រាសខ្នាតតូចបំផុត



សហគ្រាសខ្នាតតូចបំផុតភាគច្រើនជាអាជីវកម្មលក្ខណៈគ្រួសារដែលមានសមាជិកគ្រួសារជាអ្នកជួយក្នុងសកម្មភាពអាជីវកម្ម។ សហគ្រាសទាំងនោះភាគច្រើនមានបុគ្គលិកតិចជាង ១០ នាក់ ដែលភាគច្រើនជាសមាជិកក្រុមគ្រួសារ។ សហគ្រាសប្រភេទនេះសំបូរបែបណាស់ នៅតាមបណ្តាខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា។

### សហគ្រាសខ្នាតតូច

សហគ្រាសខ្នាតតូចភាគច្រើនមានសមាជិកចាប់ពី ១០ ទៅ ៥០ នាក់ ហើយដែលមានទីតាំងនៅទីប្រជុំជន និងជាយក្រុង។ សហគ្រាសប្រភេទនេះអាចជា សហគ្រាសផលិតម្ហូបអាហារ គ្រឿងសង្ហារឹម គ្រឿងតុបតែង ។ល។

### សហគ្រាសខ្នាតមធ្យម

ជាប្រភេទសហគ្រាសដែលមានទីតាំងស្ថិតនៅ ទីប្រជុំជន ឬទីរួមស្រុក ឬខេត្ត។ សហគ្រាសប្រភេទនេះជាទូទៅកាន់កាប់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងជាទូទៅមានសមាជិកចាប់ពី ៥១ ដល់ ១០០ នាក់។

## ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង

ការត្រួតពិនិត្យផ្ទៃក្នុងគឺជាកត្តាដ៏សំខាន់សម្រាប់គ្រប់ក្រុមហ៊ុន និងស្ថាប័ននានាដែលជួយឱ្យប្រតិបត្តិការប្រចាំថ្ងៃរបស់ស្ថាប័នទាំងមូលទទួលបានជោគជ័យ និងជួយឱ្យស្ថាប័នសម្រេចគោលដៅប្រកបដោយប្រសិទ្ធភាព។ គ្រឹះស្ថានជាច្រើនមិនអាចគ្រប់គ្រងការចំណាយ និងការគៃបន្លំបានដោយសារការត្រួតពិនិត្យផ្ទៃក្នុងទន់ខ្សោយ ឬគ្មានប្រសិទ្ធភាព។

**សហការ** បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបានយ៉ាងល្អប្រសើរដើម្បីការពារទ្រព្យសម្បត្តិរបស់ស្ថាប័ន ធ្វើអោយកាន់តែប្រសើរឡើងនូវសេវាបម្រើអតិថិជន ការពារនិងកាត់បន្ថយកំហុសឆ្គងនានាដែលអាចកើតឡើងដោយចេតនា ឬអចេតនា ដើម្បីធានាថាគ្រប់បុគ្គលិកទាំងអស់គោរពគោលការណ៍ និងសេចក្ដីណែនាំផ្សេងៗ។

គោលនយោបាយ និងនីតិវិធីរបស់ សហការ គឺត្រូវបានត្រួតពិនិត្យពីគ្រប់ផ្នែកដែលពាក់ព័ន្ធនិងត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ស្ថាប័នទាំងមូល។ ការបែងចែកកាតព្វកិច្ចច្បាស់លាស់ និងការត្រួតពិនិត្យលើការងារទ្វេរដងគឺជាលំហូរការងារដែលល្អបំផុតដើម្បីជៀសវាងមិនឱ្យបុគ្គលិកធ្វើប្រតិបត្តិការទាំងមូលបានតែម្នាក់ឯង។ បុគ្គលិកគ្រប់រូបត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរៀងខ្លួន និងគោរពទៅតាមគោលនយោបាយគ្រប់គ្រងហានិភ័យនិងត្រួតពិនិត្យផ្ទៃក្នុងអោយបានខ្ជាប់ខ្ជួន។ លើសពីនេះទៅទៀតថ្នាក់គ្រប់គ្រងត្រូវតែក្រើនរំលឹកដល់បុគ្គលិកថ្នាក់ក្រោមរបស់ខ្លួនអោយគោរពតាមគោលនយោបាយ និងសេចក្ដីណែនាំផ្សេងៗរបស់ស្ថាប័នជានិច្ច។

គ្រប់បុគ្គលិកទាំងអស់មានតួនាទីគ្រប់គ្រងហានិភ័យក្នុងការទទួលខុសត្រូវរៀងៗខ្លួននិងស្ថាប័នទាំងមូល។ គ្រប់បុគ្គលិកទាំងអស់មិនថា គណៈគ្រប់គ្រង នាយក នាយិកា និងប្រធានផ្នែក គឺត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងដោយប្រការណាមួយជាប្រចាំ។

ដើម្បីឱ្យការត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពខ្ពស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ បានបង្កើតឱ្យមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ជានាយកដ្ឋានឯករាជ្យដែលធ្វើការពិនិត្យនិងវាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអនុវត្តដោយបុគ្គលិកនិងថ្នាក់គ្រប់គ្រងរបស់ សហការ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងរាយការណ៍ទៅគណៈកម្មការសវនកម្មថ្នាក់ក្រុមប្រឹក្សាភិបាលដោយផ្ទាល់។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងប្រតិបត្តិតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពី "ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ចំពោះការរៀបចំរចនាសម្ព័ន្ធនៃសវនកម្មផ្ទៃក្នុង គោលបំណងនៃមុខងារសវនកម្មផ្ទៃក្នុង ធនធាន យុទ្ធសាស្ត្រ និងនីតិវិធីសវនកម្ម។

ក្នុងឆ្នាំ ២០២០ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានបញ្ចប់ កិច្ចការងារសវនកម្ម ដោយគ្រប់ដណ្ដប់ការធ្វើសវនកម្មលើប្រតិបត្តិការសំខាន់ៗ និងធ្វើការស៊ើបអង្កេតលើសកម្មភាពជាក់លាក់មួយចំនួន។

លទ្ធផលសវនកម្ម និងសមិទ្ធិផលប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ បានបង្ហាញថា ឥណទានដែលបានផ្ដល់ឱ្យអតិថិជនស្របតាមគោលនយោបាយនានានៅតែមានកម្រិតមួយល្អប្រសើរសម្រាប់ស្ថាប័នបើទោះបីជាមានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ ។ បុគ្គលិកគ្រប់ជាន់ថ្នាក់បានបំពេញការងាររបស់ខ្លួនបានល្អប្រសើ និងអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងមានប្រសិទ្ធភាព។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## អំពីក្រុមហ៊ុនយើង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ("ក្រុមហ៊ុន") គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្រោមលេខចុះបញ្ជី ០០០០៥៨៥៤ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ។

អាស័យដ្ឋានចុះបញ្ជី និងអាស័យដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុន គឺមានទីតាំងនៅផ្ទះលេខ ២០៦E0E១ ផ្លូវលេខ ១៥៥ ភូមិ១ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់ជូនដល់សាធារៈជននូវសេវាកម្មមីក្រូហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ទៅដល់សហគ្រាសខ្នាតតូច និងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់កាលបរិច្ឆេទ និងស្ថានភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចសម្រាប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ក្រុមប្រឹក្សាភិបាលមិនមានសេចក្តីណែនាំអំពីការបែងចែកភាគលាភក្នុងកាលបរិច្ឆេទនេះឡើយ។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ គឺមានបង្ហាញដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក បុល វ៉ាន់នៀត | ប្រធាន និងនាយកប្រតិបត្តិ |
| លោក. Yamashita Takahiro | អភិបាល |
| លោក. Miyauchi Toshihiro | អភិបាលឯករាជ្យ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងសម្រាប់ចុងការិយបរិច្ឆេទនេះត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ហ្គ្រេនសនថុន (ខេមបូឌា) លីមីធីត។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ អំពី ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ របស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តគោលនយោបាយគណនេយ្យសមស្របដោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មាន ដោយសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ប្រកបដោយសង្គតិភាព

(ខ) អនុវត្តតាមការតម្រូវនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ឬប្រសិនបើមានគម្លាតនៃការអនុវត្តន៍ស្តង់ដារ ដែលដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គម្លាតទាំងនោះគួរតែត្រូវបានបង្ហាញ ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឱ្យបានសមរម្យ។

(គ) រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាព លើកលែងតែក្នុងករណីដែលក្រុមហ៊ុន មិនអាចបន្តសកម្មភាពអាជីវកម្មរបស់ខ្លួននាពេលអនាគត។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុន ឱ្យមានប្រសិទ្ធភាព និងចូលរួម រាល់សេចក្តី
សម្រេចជាសារវន្ត ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនហើយក៏ត្រូវចាត់វិធានការឱ្យបានសមស្របដើម្បីទប់ស្កាត់និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមជាមួយនឹងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់នានា ត្រូវបានរៀប ចំឡើងយ៉ាងសមរម្យ និងបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាកាលបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទចុងឆ្នាំ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ អង្គភាពអាជីវកម្មខ្នាតតូច និងមធ្យម និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ជំនួសអោយក្រុមប្រឹក្សាភិបាល




លោក បុល វ៉ាន់នៀត
ប្រធាន និងនាយកប្រតិបត្តិ
ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

# របាយការណ៍របស់សវនករឯករាជ្យ
# ជូនចំពោះភាគទុនិករបស់
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ("ក្រុមហ៊ុន") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ របាយការណ៍ ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងសេចក្តីសង្ខេបទៅលើគោលការណ៍គណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ទៅលើព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ រួមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ("CIFRS for SMEs") រួមទាំងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ("NBC") ។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតនៅក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំគឺឯករាជ្យពីក្រុមហ៊ុន អនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ "ក្រមសីលធម៌ របស់គណនេយ្យករជំនាញ ("IESBA Code") រួមជាមួយនិងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងបានទទួល គឺគ្រប់គ្រាន់និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានផ្តល់នូវមតិយោបល់របស់ខ្លួនលើរបាយការណ៍ហិរញ្ញវត្ថុនាថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០ ដោយបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងគឺត្រូវទទួលខុសត្រូវរាល់ព័ត៌មានផ្សេងៗ។ រាល់ព័ត៌ដែលបានបង្ហាញនាកាលបរិច្ឆេទ នៃរបាយការណ៍នេះ បានរាយការណ៍នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងទេ ដែលយើងបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងទុកថាអាចរកបានសម្រាប់បន្ទាប់ពីកាលបរិច្ឆេទនោះ។ មតិរបស់យើងខ្ញុំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្រប់ដណ្តប់ទាំងស្រុងទៅលើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនបង្ហាញពីទម្រង់បែបបទនៃការធានាណាមួយនៃសេចក្តីសន្និដ្ឋាននោះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញកំហុសឆ្គងជាសារវន្ត។

ប្រសិនបើព័ត៌មានផ្សេងៗនេះ ដែលយើងខ្ញុំបានទទួលមុនថ្ងៃនៃរបាយការណ៍សវនករ របស់យើងខ្ញុំអាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានរបាយការណ៍ខុសជាសារវន្ត យើងខ្ញុំត្រូវតម្រូវឱ្យរាយការណ៍បញ្ហាទាំងនេះ ទៅក្រុមប្រឹក្សាភិបាល និងឆ្លើយតបបញ្ហាផ្សេងៗ ដោយអនុលោមតាមតម្រូវការ CISA ៧២០ (បានកែប្រែ)។

## ការទទួលខុសត្រូវរបស់ក្រុមគណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា សម្រាប់អង្គភាពអាជីវកម្មខ្នាតតូច និងមធ្យម ("CIFRS for SMEs") ក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិដោយផ្អែកលើមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការរៀបចំរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយផ្អែកលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវរបាយការណ៍ខុសជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើអោយប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងការសង្ស័យដែលមានវិជ្ជាជីវៈទៅតាមការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

ក. កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសដោយអចេតនាដោយសារការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

ខ. ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្រប ទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង របស់ក្រុមហ៊ុននោះទេ។

គ. ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យ ប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមគណៈគ្រប់គ្រង។

ឃ. សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមគណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើ ភស្តុតាងសវនកម្មដែលបានទទួល ថាតើភាពមិនប្រាកដប្រជា ជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។

ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

ង. វាយតម្លៃការបង្ហាញទូទៅ ទម្រង់ និងអត្ថន័យរបស់របាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញការធ្វើសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតធំៗ មួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំបានរកឃើញកំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយពួកយើងធ្វើការប្រាស្រ័យទាក់ទងជាមួយនឹង ក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

Grant Thornton

ហ្គ្រេន សនថុន ខេមបូឌា លីមីតធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់៣.២) |
| | | | | | |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៩៣,៥៨៩ | ៣៧៨,៥៦៨ | ៤៩,៩៥៦ | ២០៣,៥៧១ |
| ប្រាក់តម្កល់ និងសាច់ប្រាក់ជំនួសជាមួយ | | | | | |
| ធនាគារជាតិនៃកម្ពុជា ("NBC") | ៧ | ១៧១,៧២១ | ៦៩៤,៦១១ | ១២១,៣៧២ | ៤៩៤,៥៩១ |
| ប្រាក់តម្កល់ និងសាច់ប្រាក់ជំនួសជាមួយ | | | | | |
| ធនាគារផ្សេង | ៨ | ២១៤,២៥២ | ៨៦៦,៦៤៩ | ៤៣២,០៩៧ | ១,៧៦០,៧៩៥ |
| កម្ចីទៅឱ្យអតិថិជនសុទ្ធ | ៩ | ៥,២៥៩,៦៩៥ | ២១,២៧៥,៤៦៦ | ៣,៣៣៦,៨៨៣ | ១៣,៥៩៧,៧៩៨ |
| ទ្រព្យសកម្មផ្សេងទៀត | ១០ | ១៩,១០៥ | ៧៧,២៨០ | ៣៨,១៩៧ | ១៥៥,៦៥៣ |
| ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារ | ១១ | ១០៩,៣៥៥ | ៤៤២,៣៤១ | ១២០,៧៨១ | ៤៩២,១៨៣ |
| ទ្រព្យសកម្មអរូបី | ១២ | ៤២ | ១០៧ | ២០១ | ៨១៩ |
| ពន្ធពន្យារលើទ្រព្យសកម្ម | ១៣.៤ | ៧៨,៣០៨ | ៣១៦,៧៥៦ | ៧២,១៧៦ | ២៩៤,១១៧ |
| **ទ្រព្យសកម្មសរុប** | | **៥,៩៤៦,០៦៧** | **២៤,០៥១,៨៤១** | **៤,១៧១,៦៦៣** | **១៦,៩៩៩,៥២៧** |
| | | | | | |
| **បំណុល និងមូលធន** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៣,៣០០,០០០ | ១៣,២៧៧,០០០ | ១,៨០០,០០០ | ៧,២០០,០០០ |
| ការបញ្ចូលដើមទុនបន្ថែម | ១៦ | - | - | ៥០០,០០០ | ២,០០០,០០០ |
| ការខាតបង្គរ | | (១,៩៨១,០៦៣) | (៨,០១១,៣៥៥) | (១,៩១៥,៣២៩) | (៧,៨០៤,៩៦៦) |
| ទុនបម្រុងតាមបទបញ្ញត្តិ | ១៧ | ៧,៦៣៦ | ៣០,៦៨១ | ៧,៦៣៦ | ៣០,៦៨១ |
| លម្អៀងពីការប្តូររូបិប័ណ្ណ | | - | ៦៩,៦៥៩ | - | ១៧២,៩៣៦ |
| **មូលធនសរុប** | | **១,៣២៦,៥៧៣** | **៥,៣៦៥,៩៨៧** | **៣៩២,៣០៧** | **១,៥៩៨,៦៥១** |
| **បំណុល** | | | | | |
| បំណុលផ្សេងទៀត | ១៦ | ១០៣,១៩៥ | ៤១៧,៤២៤ | ៦៤,៥៨១ | ២៦៤,២៦៨ |
| ប្រាក់កម្ចី | ១៥ | ៤,៥១៥,៣២៩ | ១៨,២៦៤,៥០៦ | ៣,៧១៣,៥៣៥ | ១៥,១៣២,៦៥៥ |
| បំណុលពន្ធអប្បបរមា | ១៣.៥ | ៩៧០ | ៣,៩២៤ | ៩៧០ | ៣,៩៥៣ |
| **បំណុលសរុប** | | ៤,៦១៩,៤៩៤ | ១៨,៦៨៥,៨៥៤ | ៣,៧៧៩,៣៥៦ | ១៥,៤០០,៨៧៦ |
| **មូលធន និងបំណុលសរុប** | | **៥,៩៤៦,០៦៧** | **២៤,០៥១,៨៤១** | **៤,១៧១,៦៦៣** | **១៦,៩៩៩,៥២៧** |

# របាយការណ៍ចំណូលលម្អិត

## នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់៣.២) | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់៣.២) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១៨ | ៧៣៥,៥៩៥ | ២,៩៩៩,០២១ | ៧៥០,៥៨២ | ៣,០៤១,៣៥៨ |
| ចំណាយការប្រាក់ | ១៩ | (១៨៥,១៤៧) | (៧៥៤,៨៤៤) | (៣៨៥,៨៧៤) | (១,៥៦៣,៥៦១) |
| ចំណូលការប្រាក់សរុបសុទ្ធ | | ៥៥០,៤៤៨ | ២,២៤៤,១៧៧ | ៣៦៤,៧០៨ | ១,៤៧៧,៧៩៧ |
| ចំណូលសេវា និងកម្រៃជើងសារ | | - | - | ១១,៤៨២ | ៤៦,៥២៥ |
| ចំណូលប្រតិបត្តិការផ្សេងៗទៀត | ១៩ | ២១៣,៥៧៣ | ៨៧០,៧៣៧ | ៥៦,៣២៥ | ២២៨,២២៩ |
| **ចំណូលប្រតិបត្តិការសរុប** | | ៧៦៤,០២១ | ៣,១១៤,៩១៤ | ៤៣២,៥១៥ | ១,៧៥២,៩៥១ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២០ | (៧៨៣,៥៧៣) | (៣,១៩៤,៦២៧) | (៧២០,៤៤២) | (២,៩១៩,២៣១) |
| ការខាតបង់លើឱនភាព | | | | | |
| នៃទ្រព្យសកម្ម | | | | | |
| ហិរញ្ញវត្ថុ | ៩ | (៤១,៨៤៩) | (១៧០,៦១៨) | (១,១៣៣,៧៤៩) | (៤,៥៩៣,៩៥១) |
| ខាតបង់មុនគិតពន្ធលើបាក់ចំណូល | | (៦១,៤០១) | (២៥០,៣៣១) | (១,៤២១,៦៧៦) | (៥,៧៦០,៦៣១) |
| ចំណាយពន្ធអប្បបរមា | ១៣.១ | (១០,៤៦៥) | (៤២,៦៦៦) | (៨,៣២០) | (៣៣,៧១៣) |
| ឥណទានពន្ធលើប្រាក់ចំណូល | ១៣.៤ | ៦,១៣២ | ២៥,០០០ | ៣១,០៨៦ | ១២៥,៩៦០ |
| ការខាតបង់សុទ្ធសម្រាប់ | | | | | |
| ការិយបរិច្ឆេទ | | (៦៥,៧៣៤) | (២៦៧,៩៩៧) | (១,៣៩៨,៩១០) | (៥,៦៦៨,៣៨៤) |
| ចំណូលលម្អិតផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៤១,៦៦៧) | - | ៧៨,៩២៣ |
| ការខាតបង់សរុបសម្រាប់ | | | | | |
| **ការិយបរិច្ឆេទ** | | (៦៥,៧៣៤) | (៣០៩,៦៦៤) | (១,៣៩៨,៩១០) | (៥,៥៨៩,៤៦១) |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ការខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ១,៨០០,០០០ | ៧,៥០០,០០០ | ៥០០,០០០ | ២,០០០,០០០ | ៧,៦៣៦ | ៣០,៦៨១ | (១,៩១៥,៣២៩) | (៧,៧៤៣,៣៥៦) | ១១១,៣២៦ | ៣៩២,៣០៧ | ១,៥៩៨,៦៥១ |
| បន្ថែមដើមទុន | ១,៥០០,០០០ | ៦,០៧៧,០០០ | (៥០០,០០០) | (២,០០០,០០០) | - | - | - | - | - | ១,០០០,០០០ | ៤,០៧៧,០០០ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | (៦៥,៧៣៤) | (២៦៧,៩៨៧) | - | (៦៥,៧៣៤) | (២៦៧,៩៨៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (៤១,៦៦៧) | - | (៤១,៦៦៧) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០** | **៣,៣០០,០០០** | **១៣,២៧៧,០០** | **-** | **-** | **៧,៦៣៦** | **៣០,៦៨១** | **( ១,៩៨១,០៦៣ )** | **( ៨,០១១,៣៤៣ )** | **៦៩,៦៥៩** | **១,៣២៦,៥៧៣** | **៥,៣៦៥,៩៨៧** |

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ការខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) | ( សម្គាល់៣.២ ) | | ( សម្គាល់៣.២ ) |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ១,៨០០,០០០ | ៧,២០០,០០០ | - | - | ៧,៦៣៦ | ៣០,៦៨១ | (៥១៦,៤១៩) | (២,០៧៤,៩៧)) | ៣២,៤០៣ | ១,២៩១,២១៧ | ៥,១៨៨,១១២ |
| បន្ថែមដើមទុន | - | - | ៥០០,០០០ | ២,០០០,០០០ | - | - | - | - | - | ៥០០,០០០ | ២,០០០,០០០ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | (១,៣៩៨,៩១០) | (៥,៦៦៨,៣៤) | - | (១,៣៩៨,៩១) | (៥,៦៦៨,៣៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ៧៨,៩២៣ | - | ៧៨,៩២៣ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩** | **១,៨០០,០០០** | **៧,២០០,០០០** | **៥០០,០០០** | **២,០០០,០០០** | **៧,៦៣៦** | **៣០,៦៨១** | **( ១,៩១៥,៣២៩ )** | **( ៧,៧៤៣,៣៥ )** | **១១១,៣២៦** | **៣៩២,៣០៧** | **១,៥៩៨,៦៥១** |

# របាយការណ៍លំហូរសាច់ប្រាក់

## នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០

| | | សម្រាប់ចុងការិយបរិច្ឆេទ | | សម្រាប់ចុងការិយបរិច្ឆេទ | |
|---|---|---|---|---|---|
| | កំណត់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| ខាតបង់សុទ្ធក្នុងការិយបរិច្ឆេទ | | (៦១,៤០១) | (២៥០,៣៣១) | (១,៤២១,៦៧៦) | (៥,៧៦០,៦៣១) |
| **ការកែតម្រូវសម្រាប់៖** | | | | | |
| រំលស់ និងរំលស់លើទ្រព្យសកម្មអរូបី | ១១&១២ | ៥៤,០២៨ | ២២០,២៧២ | ៦១,៤៩៤ | ២៤៩,១៧៤ |
| ការខាតបង់លើឱនភាពសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ | ៩ | ៤១,៨៤៩ | ១៧០,៦១៨ | ១,១៣៣,៧៤៩ | ៤,៥៩៣,៩៥១ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារ | ២០ | (១៥,១៦៤) | (៦១,៨២៤) | (២,០៤៥) | (៨,២៨៨) |
| **ប្រាក់ចំណូលប្រតិបត្តិការ/(ខាតបង់) មុនធ្វើការផ្លាស់ប្តូរដើមទុន** | | **១៩,៣១២** | **៧៨,៧៣៥** | **(២០៥,៧១២)** | **(៨៣៣,៥៤៧)** |
| **បម្រែបម្រួលក្នុង ៖** | | | | | |
| ប្រាក់ធានាដើមទុន | | (៥០,០០០) | (២០៣,៨៥០) | - | - |
| កម្ចីទៅឱ្យអតិថិជន | | (១,៩៦៤,៦៦១) | (៨,០០៩,៩២៣) | ៨៤៨,៩៤២ | ៣,៤៣៩,៩១៤ |
| ទ្រព្យសកម្មផ្សេងទៀត | | ១៩,០៩២ | ៧៧,៨៣៨ | ៨,១៦៣ | ៣៣,០៧៦ |
| បំណុលផ្សេងទៀត | | ៣៨,៣៤៤ | ១៥៦,៣២៨ | ៤,៦៦២ | ១៨,៨៩០ |
| **សាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | **(១,៩៣៧,៩១៣)** | **(៧,៩០០,៨៧២)** | **៦៣៣,២៨៩** | **២,៥៦៦,០៨៦** |
| ពន្ធអប្បបរមាដែលបានទូទាត់ | ១៣.៥ | (១០,៤៦៥) | (៤២,៦៦៦) | (៧,៧៩៤) | (៣១,៥៨១) |
| **សាច់ប្រាក់សុទ្ធដែលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | | **(១,៩៤៨,៣៧៨)** | **(៧,៩៤៣,៥៣៨)** | **៦២៥,៤៩៥** | **២,៥៣៤,៥០៥** |
| | | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ និងឧបរណ៍បរិក្ខារ និងទ្រព្យសកម្មអរូបី | ១១&១២ | (៤២,៤៤៣) | (១៧៣,០៤០) | (៦៦,៧២៣) | (២៧០,៣៦១) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និង ឧបរណ៍បរិក្ខារ | | ១៥,១៦៤ | ៦១,៨២៤ | ៤៥,៣២០ | ១៨៣,៦៣៧ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(២៧,២៧៩)** | **(១១១,២១៦)** | **(២១,៤០៣)** | **(៨៦,៧២៤)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ទទួលដើមទុនបន្ថែមដែលបានទទួលជាមុន | ១៦ | ១,០០០,០០០ | ៤,០៧៧,០០០ | ៥០០,០០០ | ២,០២៦,០០០ |
| (ការសងត្រលប់វិញនៃ)/ ចំណេញពីប្រាក់កម្ចី | | ៨០១,៧៩៤ | ៣,២៦៨,៩១៤ | (២,០៤៩,៧០៦) | (៨,៣០៥,៤០៨) |
| **សាច់ប្រាក់សុទ្ធ(ដែលបានប្រើ)/ ដែលបានពីសកម្មភាពហិរញ្ញវត្ថុ** | | **១,៨០១,៧៩៤** | **៧,៣៤៥,៩១៤** | **(១,៥៤៩,៧០៦)** | **(៦,២៧៩,៤០៨)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សុទ្ធនៅក្នុងគ្រា** | | **(១៧៣,៨៦៣)** | **(៧០៨,៨៤០)** | **(៩៤៥,៦១៤)** | **(៣,៨៣១,៦២៧)** |
| សាច់ប្រាក់ និងសាច់ប្រាក់សុទ្ធនៅដើមការិយបរិច្ឆេទ | | ៤៨៨,៤២៥ | ១,៩៩០,៣៣២ | ១,៤៣៤,០៣៩ | ៥,៧៦១,៩៦៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៩,០៨៩) | - | ៥៩,៩៩១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | ២១ | **៣១៤,៥៦២** | **១,២៧២,៤០៣** | **៤៨៨,៤២៥** | **១,៩៩០,៣៣២** |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ១. អំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ("ក្រុមហ៊ុន") គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្រោមលេខចុះបញ្ជី ០០០០៥៨៥៤ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥។

អាស័យដ្ឋានចុះបញ្ជី និងអាស័យដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុនគឺមានទីតាំងនៅផ្ទះលេខ ២០៦អឺ០អឺ១ ផ្លូវលេខ១៥៥ ភូមិ១ សង្កាត់ទូលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ២. ការអនុលោមនៃរបាយការណ៍

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយអនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាព ខ្នាតតូចនិងមធ្យម (CIFRS for SMEs) បោះផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសលេខ ០៦៨ -សហវ-ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ និងក្រុមប្រឹក្សាគណនេយ្យកម្ពុជាក្រោមសារាចរលេខ ០៩៧/០៩ MEF ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជារូបិយប័ណ្ណដុល្លារអាមេរិក ("USD") ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។

## ៣. សេចក្តីសង្ខេបគោលការណ៍គណនេយ្យ

### ៣.១ សេចក្តីសម្រេចទូទៅ និងការអនុម័តជាលើកដំបូងតាមស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ( CIFRS for SMEs )

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងសង្គតិភាពគ្រប់ការិយបរិច្ឆេទទាំងអស់ ដែលបានបញ្ចេញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបង្ហាញជាក់លាក់ដទៃទៀត។

### ៣.២ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណក្នុងការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺខ្មែររៀល ("រៀល")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់រូបិយប័ណ្ណដុល្លារអាមេរិក ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍និងកាលៈទេសៈរបស់ក្រុមហ៊ុន។ ប្រតិបត្តិការរូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានបកប្រែទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិកា។

ទ្រព្យសកម្ម ឬបំណុលដែលកំណត់ជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិក នៅកាលបរិច្ឆេទនៃរបាយការណ៍ ត្រូវបានបកប្រែទៅជាដុល្លារអាមេរិកដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃរបាយការណ៍។ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលបានកើតឡើងពីការបកប្រែត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀល បានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុគឺក្នុងគោលបំណងដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ព្រមទាំងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដូចដែលបានប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារ៖

| | សម្រាប់ឆ្នាំ២០២០ | សម្រាប់ឆ្នាំ២០១៩ |
|---|---|---|
| អត្រាមធ្យម | ៤០៧៧ | ៤០៥២ |
| អត្រាចុងគ្រា | ៤០៤៥ | ៤០៧៥ |

របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាប្រាក់រៀល គឺមិនត្រូវបានធ្វើសវនកម្មឡើយ ហើយមិនគួរត្រូវបានបកស្រាយថាជាតំណាងឱ្យចំនួនទឹកប្រាក់ដុល្លារអាមេរិកដែលត្រូវបាន ឬអាចត្រូវបានបំលែងជាប្រាក់រៀលនៅក្នុងអត្រាប្តូរប្រាក់ក្នុងការិយបរិច្ឆេទនេះ ឬអត្រាប្តូរប្រាក់ដទៃផ្សេងទៀត។

## ៣.៣ មូលដ្ឋាននៃការរួមបញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលគ្នាទាំងរបាយការណ៍របស់ស្នាក់ការកណ្តាល និងសាខាផ្សេងទៀតរបស់ក្រុមហ៊ុនបន្ទាប់ពីបានលុបចោលនូវសមតុល្យ និងប្រតិបត្តិការរបស់អន្តរសាខាសំខាន់ៗ។

## ៣.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងប្រាក់បញ្ញើរដែលមាននៅជាមួយធនាគារដទៃ។

## ៣.៥ ប្រាក់បញ្ញើរតម្កល់តាមបទបញ្ញត្តិធនាគារជាតិនៃកម្ពុជា ( NBC )

ប្រាក់បញ្ញើរ តម្កល់តាមបទបញ្ញត្តិនៅធនាគារជាតិនៃកម្ពុជាត្រូវបានកត់ត្រាតាមតម្លៃដើម ដែលរួមមានប្រាក់តម្កល់ធានាលើដើមទុនសាច់ប្រាក់រក្សាទុកនៅធនាគារជាតិនៃកម្ពុជា អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហរិញ្ញវត្ថុ និងមិនអាចប្រើប្រាស់នៅក្នុងសកម្មភាពប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃរបស់ក្រុមហ៊ុនបានទេ។ អាស្រ័យហេតុនេះប្រាក់បញ្ញើរតម្កល់តាមបទបញ្ញត្តិនេះមិនត្រូវបានគិតជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសម្រាប់គោលបំណងនៃលំហូរសាច់ប្រាក់។

## ៣.៦. ឥណទានផ្តល់ទៅឱ្យអតិថិជន

ឥណទានបានផ្តល់ទៅឱ្យអតិថិជន ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របណាមួយដែលរាប់បញ្ចូលដោយផ្ទាល់ក្នុងចំណាយប្រតិបត្តិការ។ នៅពេលដែលឥណទានត្រូវបានពង្រីកលើសពីលក្ខខណ្ឌឥណទានធម្មតា គណនីត្រូវទទួលគឺត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។

នៅចុងការិយបរិច្ឆេទនៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ចំនួនទឹកប្រាក់យោងនៃគណនីត្រូវទទួលគឺត្រូវបានពិនិត្យឡើងវិញកំណត់ថាតើមានភស្តុតាងជាក់លាក់ណាមួយដែលថាចំនួនទឹកប្រាក់នោះមិនអាចប្រមូលមកវិញបានទេ។ ឥណទានដែលបានលុបចេញពីបញ្ជីទៅក្នុងរបាយការណ៍ចំណូលពេញលេញនៅពេលដែលឥណទានត្រូវបានគិតសំវិធានធននៅក្នុងតម្លៃពេញ និងតម្លៃនៅសល់ដែលមិនទាន់បានបង់បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយ ឬនៅពេលដែលតម្លៃជាក់លាក់នៃឥណទានដែលនៅសល់។ ឥណទានដែលបានលុបចោលត្រូវបានដកចេញពីតម្លៃនៅសល់ និងដកជាមួយសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ។

ការប្រមូលបានមកវិញនូវឥណទានដែលបានលុបចេញពីបញ្ជីពីមុន ត្រូវបានបង្ហាញជាប្រាក់ចំណូលប្រតិបត្តិការផ្សេងៗនៅក្នុងរបាយការណ៍ចំណូលលម្អិត។

### ៣.៧. ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតគឺត្រូវបានយោងតាមថ្លៃដើម។ ការប៉ាន់ស្មានគឺត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យដែលអាចប្រមូលមកវិញបាន ដោយអាស្រ័យទៅលើការត្រួតពិនិត្យឡើងវិញនៃចំនួនទឹកប្រាក់ដែលនៅជំពាក់នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ។

### ៣.៨. ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារ

ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារត្រូវបានកត់តាមតម្លៃដើមដករំលស់បង្គរនិងខាតបង់លើឱនភាពតម្លៃ។ ថ្លៃដើមរួមបញ្ចូលទាំងការចំណាយដែលត្រូវបានបង្កឡើងដោយផ្ទាល់ទៅនឹងការទទួលបានទ្រព្យសម្បត្តិ។

ការចំណាយជាបន្តបន្ទាប់ ត្រូវបានរាប់បញ្ចូលក្នុងចំនួនទឹកប្រាក់នៃការកាន់កាប់ទ្រព្យសម្បត្តិ ឬត្រូវបានគេទទួលស្គាល់ថាជាទ្រព្យសម្បត្តិដាច់ដោយឡែកបើសមស្របនៅពេលចំណាយត្រូវបានកើតឡើង ហើយវាអាចនឹងមានអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចនាពេលអនាគតដែលទាក់ទងនឹងទ្រព្យនោះនឹងហូរចូលក្រុមហ៊ុននិងថ្លៃដើមនៃទ្រព្យសកម្មអាចត្រូវបានវាស់វែងដោយទុកចិត្ត។ តម្លៃយោងនៃផ្នែកនីមួយៗដែលបានជំនួស គឺមិនត្រូវបានទទួលស្គាល់។ តម្លៃនៃការប្រើប្រាស់ទ្រព្យ និងបរិក្ខារពីមួយថ្ងៃទៅមួយថ្ងៃត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតដែលចំណាយទាំងនោះបានកើតឡើង។ ចំណាយក៏រួមបញ្ចូលជាមួយនឹងថ្លៃដើមដែលបានប៉ាន់ស្មាននៃការដកចេញ និងការបំលាស់ប្តូរទ្រព្យសកម្ម និងរៀបចំឡើងវិញនូវទីតាំងដែលទ្រព្យ និងបរិក្ខារកំពុងស្ថិតនៅសម្រាប់ក្រុមហ៊ុនមានកាតព្វកិច្ចកើតឡើងនៅពេលដែលទ្រព្យសកម្មត្រូវបាន ប្រសិនបើអាច។

ផ្នែកនីមួយៗនៃទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារជាមួយនឹងថ្លៃដើមដែលមានទំនាក់ទំនងសំខាន់ៗទៅនឹងថ្លៃដើមសរុបទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារដែលមានអាយុកាលប្រើប្រាស់ខុសគ្នា ត្រូវបានរំលស់ផ្សេងគ្នា។

បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារត្រូវបានកំណត់នូវថ្លៃដើមដករំលស់បង្គរ និងខាតបង់លើឱនភាពនៃតម្លៃបង្គរផ្សេងៗ។

រំលស់លើទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារ ត្រូវបានគិតជាចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិតលើមូលដ្ឋានរំលស់តាមវិធីសាស្ត្រថយជាលំដាប់ លើកលែងតែការកែលម្អទ្រព្យជួលរំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារនីមួយៗ អាយុកាលប្រើប្រាស់មានដូចខាងក្រោម៖

| | អាយុកាលប្រើប្រាស់ |
|---|---|
| គ្រឿងសង្ហារឹម និងឧបករណ៍ និងឧបករណ៍ការិយាល័យអត្រាចុងគ្រា | ៤ឆ្នាំ |
| យានយន្ត ម៉ូតូ | ២ឆ្នាំ |
| យានយន្ត ម៉ូតូ | ៥ឆ្នាំ |

នៅក្នុងករណីនៃការកែលម្អទ្រព្យជួល អាយុកាលដែលបានប៉ាន់ស្មានគឺខ្លីជាងរវាងអាយុកាលមានប្រយោជន៍នៃការជួល ឬរយៈពេលជួល។

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងមូលដ្ឋានរំលស់ត្រូវបានពិនិត្យឡើងវិញ និងកែតម្រូវតាមការរំពឹងទុក ប្រសិនបើសមរម្យ ប្រសិនបើការបង្ហាញពីការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយ។

តម្លៃយោងនៃទ្រព្យសកម្មត្រូវបានលប់ចោលភ្លាមៗ ទៅតាមចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន ប្រសិនបើតម្លៃយោងរបស់វាធំជាងចំនួនដែលបានប៉ាន់ស្មាននៃទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

ចំណេញ ឬខាតពីការលក់ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់ដែលបានពីការលក់ និងតម្លៃយោងរបស់វា និងត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណូលលម្អិត។

ទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារដែលបានធ្វើរំលស់ ត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ពេលលក់ចេញនិងជម្រះចេញពីបញ្ជី។

### ៣.៩. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានកុំព្យូទ័រសូហ្វវែរ ហើយត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ ការទិញកុំព្យូទ័រសូហ្វវែរ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋាន ថ្លៃដើមដែលបានទិញ និងនាំយកសូហ្វវែរនោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបីត្រូវបានរំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរតាមអត្រា ១០%ក្នុងមួយឆ្នាំ។ ប្រសិនបើមានការចង្អុលបង្ហាញថាមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់លើអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃសំណល់នៃទ្រព្យសកម្មអរូបី នោះការធ្វើរំលស់និងត្រូវបានកែប្រែដោយមានចក្ខុវិស័យឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

### ៣.១០. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានទទួលស្គាល់ដំបូងតាមថ្លៃដើមប្រតិបត្តិការ និងកំណត់ជាបន្តបន្ទាប់តាមថ្លៃដើមដែលបានរំលស់។ ចំណាយការប្រាក់ គឺត្រូវបានទទួលស្គាល់តាមមូលដ្ឋាននៃវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### ៣.១១. អត្ថប្រយោជន៍បុគ្គលិក

#### ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

ប្រកាសលេខ ៤៤៣ បានចេញផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតម្រូវឱ្យក្រុមហ៊ុនបើករំលឹកប្រាក់បំណាច់អតីតភាពការងារទៅឱ្យនិយោជិតដែលមានកិច្ចសន្យាការងារមិនមានកំណត់ថេរវេលា។ និយោជិតទាំងអស់ដែលបានបម្រើការងារមុនថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងបន្តបម្រើការងារឱ្យអង្គភាពនឹងទទួលបានប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួល ១៥ថ្ងៃ នៅក្នុង ១ឆ្នាំ ដែលមិនលើស ៦ខែ នៃប្រាក់ឈ្នួលសុទ្ធសាធគិតតាមឆ្នាំនីមួយៗ ហើយប្រាក់បំណាច់អតីតភាពការងារត្រូវបង់រៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៩ ដូចតទៅ៖

- ចំនួន ៧,៥ ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន ៧,៥ ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ

ប្រាក់រំលឹកអតីតភាពការងារត្រូវបានទទួលស្គាល់ពេញនៅក្នុងឆ្នាំ២០១៨ និងប្រាក់បំណាច់អតីតភាពការងារត្រូវបង់នាពេលអនាគត (ចំនួន ១៥ថ្ងៃ ក្នុងមួយឆ្នាំ) ទៅឱ្យនិយោជិត ត្រូវបានទទួលស្គាល់នៅក្នុងកំឡុងពេលដែលនិយោជិតបម្រើការងារ។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញនូវសារាចរណែនាំលេខ ០៤២/១៩ ស្តីពីការបង់ប្រាក់ត្រលប់នៃប្រាក់បំណាច់អតីតភាពការងារ មុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកផ្សេងទៀត ក្រៅពីផ្នែក

វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ត្រូវបានពន្យារចំពោះការបើករំលឹកប្រាក់បំណាច់អតីតភាពការងាររហូតដល់ខែធ្នូ ឆ្នាំ ២០២១ និងផ្លាស់ប្តូរការបង់ចំនួន ១៥ថ្ងៃ នៃប្រាក់ឈ្នួលមធ្យមរៀងរាល់ឆ្នាំនៃរយៈពេលបម្រើការងាររបស់និយោជិតចំនួន ៦ថ្ងៃដូចតទៅ៖

- ចំនួន ៣ ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន ៣ ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ

ចំពោះនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាកំណត់ ពួកគេត្រូវទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យានេះយ៉ាងតិចត្រូវស្មើ ៥% នៃប្រាក់ឈ្នួល ដែលនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យានោះ។

ចំពោះនិយោជិតដែលបានលាឈប់ពីការងារ នឹងមិនត្រូវទទួលបាននូវប្រាក់រំលឹកអតីតភាពការងារដែលនៅសល់នោះទេ។

### អត្ថប្រយោជន៍រយៈពេលខ្លីរបស់បុគ្គលិក

ប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ ភាគទានរបបសន្តិសុខសង្គម ចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំបានបង់ ការឈប់សម្រាកដោយសារជម្ងឺបានបង់ប្រាក់បន្ថែមលើកទឹកចិត្ត ប្រាក់បំណាច់អតីតភាពការងារ និងអត្ថប្រយោជន៍ មិនមែនជាសាច់ប្រាក់ដែលត្រូវបានវាស់វែងលើមូលដ្ឋានដែលមិនបានរាប់បញ្ចូល និងចំណាយនៅពេលដែលនិយោជិតបម្រើការងារទៅដល់ក្រុមហ៊ុន។

សំណងបង្គររយៈពេលខ្លីដែលមិនមានវត្តមាន មានដូចជាចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំបានបង់ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលនិយោជិកបម្រើការងារ ដែលមានការកើនឡើងនូវការផ្តល់សំណងដែលមិនមានវត្តមាននាពេលអនាគត។ សំណងមិនបានបង្គររយៈពេលខ្លីដែលមិនមានវត្តមាន មានដូចជាការឈប់សម្រាកដោយសារជម្ងឺត្រូវបានទទួលស្គាល់នៅពេលដែលការអវត្តមានបានកើតឡើង។ និយោជិតដែលបានអនុវត្តតាមគោលការណ៍លាឈប់ត្រឹមត្រូវគឺមិនមានសិទ្ធិទទួលបានចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមិនបានប្រើ។ និយោជិតអាចទទួលបានសំណងប្រសិនបើពួកគេមិនបានប្រើប្រាស់ចំនួនថ្ងៃឈប់សម្រាកទាំងអស់។

ប្រាក់លើកទឹកចិត្តបន្ថែមត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមាន អំណោយ ច្បាប់ ឬក៏កាតព្វកិច្ចដែលមានប្រយោជន៍ដែលធ្វើឱ្យការចំណាយ ជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល និងនៅពេលដែលការប៉ាន់ស្មានដែលអាចជឿទុកចិត្តបានអាចកើតឡើងនូវចំនួនទឹកប្រាក់កាតព្វកិច្ច។

### ៣.១២. បំណុលផ្សេងទៀត

គណនីអតិថិជន និងបំណុលផ្សេងទៀត គឺត្រូវបានទទួលស្គាល់ជាលើកដំបូងតាមតម្លៃប្រតិបត្តិការ និងបានធ្វើការវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។

### ៣.១៣. មូលធន ការទូទាត់ភាគលាភ និងកាខាតបង់បង្គរ

សន្និធិដើមទុនតំណាងឱ្យតម្លៃបន្ទាប់បន្សំ (តម្លៃចារឹក) នៃសន្លឹកហ៊ុនដែលបានបោះផ្សាយ។

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន មុនចុងការិយបរិច្ឆេទនៃរបាយការណ៍ ត្រូវបានទទួលស្គាល់ជាបំណុល និងគណនីសម្រាប់ការដកចេញពីចំណូលរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន បន្ទាប់ពីការិយបរិច្ឆេទរបាយការណ៍ គឺមិនត្រូវបានទទួលស្គាល់ជាបំណុល ប៉ុន្តែបានបង្ហាញជាព្រឹត្តិការណ៍បន្ទាប់ក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

ខាតបង្គរ គឺរួមបញ្ចូលទាំងរាល់ការខាតក្នុងការិយបរិច្ឆេទ និងការខាតពីការិយបរិច្ឆេទមុន។

## ៣.១៤. សំវិធានធនតាមបទបញ្ញត្តិ

ការចាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន ដល់គ្រឹះស្ថានហិរញ្ញវត្ថុដោយអនុលោមតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៧ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ផ្តល់ការណែនាំអំពីការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនតាមបទបញ្ញត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា ដែលបានសង្ខេបដូចខាងក្រោម៖

| ចំណាត់ថ្នាក់ឥណទាន | ចំនួនថ្ងៃហួសកាលកំណត់ | សំវិធានធន |
|---|---|---|
| ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ) | | |
| ឥណទានធម្មតា/ស្តង់ដារ | ០-២៩ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ៣០-៨៩ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៩០-១៧៩ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ១៨០-៣៥៩ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ច្រើនជាង ៣៦៥ថ្ងៃ | ១០០% |

| ចំណាត់ថ្នាក់ឥណទាន | ចំនួនថ្ងៃហួសកាលកំណត់ | សំវិធានធន |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ) | | |
| ឥណទានធម្មតា/ស្តង់ដារ | ០-១៤ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ១៥-៣០ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៣១-៦០ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ១៨០-៣៥៩ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ច្រើនជាង ៩០ថ្ងៃ | ១០០% |

មាត្រា ៧៣ នៃប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធន តម្រូវឱ្យធនាគារធ្វើការប្រៀបធៀប សំវិធានធនដែលត្រូវបានគណនាសមស្របតាម ស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងប្រកាសលេខ ធ៧-០១៧-៣៤៤ ហើយកំណត់ថា៖

១. ក្នុងករណីដែលសំវិធានធនតាមបទបញ្ញត្តិ ដែលត្រូវបានគណនាស្របតាមប្រកាស មានកម្រិតទាបជាងសំវិធានធនដែលបានគណនាស្របតាមស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមក្រុមហ៊ុនគួរតែកត់ត្រាសំវិធានធនដែលបានគណនាដោយអនុលោមតាមស្តង់ដារ ទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។

២. ក្នុងករណីដែលសំវិធានធនតាមបទបញ្ញត្តិ ដែលត្រូវបានគណនាស្របតាមប្រកាស មានកម្រិតខ្ពស់ជាង សំវិធានធនដែលបានគណនា ស្របតាមស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនា ដោយអនុលោមតាមស្តង់ដារទាក់ទង នឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមហើយផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញរក្សាទុក ឬខាតបង្គរ ទៅក្នុងប្រាក់បម្រុងតាមបទបញ្ញត្តិ ដែលជាផ្នែកមួយនៃមូលធននៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទបញ្ញត្តិមិនត្រូវរួមបញ្ចូលក្នុងការគណនាតម្លៃពិតរបស់ក្រុមហ៊ុនឡើយ។

### ៣.១៥. ចំណូល និងចំណាយការប្រាក់

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ចំណូល និងចំណាយការប្រាក់បង្ហាញនៅក្នុងរបាយការណ៍ចំណូលលម្អិតរួមបញ្ចូលទាំងការប្រាក់ទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ដែលត្រូវបានគណនាតាមមូលដ្ឋានការប្រាក់ប្រសិទ្ធភាព។

### ៣.១៦. ចំណូល និងចំណាយសេវាកម្ម និងកម្រៃជើងសារ

ចំណូល និងចំណាយសេវាកម្ម និងកម្រៃជើងសារដែលជាផ្នែកស្នូលដ៏សំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព។ ទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬក៏បំណុលហិរញ្ញវត្ថុគឺត្រូវរួមបញ្ចូលទៅក្នុងការវាស់វែងនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ចំណូលពីកម្រៃសេវាក្នុងការដំណើរការឥណទាន គឺត្រូវបានទទួលស្គាល់ជាចំណូលការប្រាក់ក្នុងរយៈពេលនៃការិយបរិច្ឆេទនៃឥណទានដែលបានផ្តល់ទៅឱ្យអតិថិជន។

### ៣.១៧. ចំណាយប្រតិបត្តិការ

ចំណាយប្រតិបត្តិការ គឺត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិតនៅក្នុងការិយបរិច្ឆេទដែលចំណាយនោះកើតឡើង។

### ៣.១៨. ភតិសន្យាប្រតិបត្តិការ

ភតិសន្យាដែលហានិភ័យមួយផ្នែកធំ និងផលនៃកម្មសិទ្ធិលើទ្រព្យសកម្មនេះ ត្រូវបានរក្សាដោយភាគីម្ចាស់ទ្រព្យ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។ ការទូទាត់ភតិសន្យាប្រតិបត្តិការ (ប្រាក់លើកទឹកចិត្តសុទ្ធដែលបានទទួលពីម្ចាស់ទ្រព្យ) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណូលលម្អិត តាមមូលដ្ឋានថេរក្នុងការិយបរិច្ឆេទនៃភតិសន្យានោះ។

### ៣.១៩. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត រួមបញ្ចូលទាំងផលបូកនៃពន្ធពន្យារ និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មិនត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណូលលម្អិត ឬទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន។

ពន្ធជាទ្រព្យសកម្ម និង/បំណុលពន្ធ គឺមានកាតព្វកិច្ច ឬការទាមទារពីអាជ្ញាធរសារពើពន្ធ ដែលពាក់ព័ន្ធក្នុងកំឡុងការិយបរិច្ឆេទបច្ចុប្បន្ន ឬឆ្នាំមុនៗ ដែលមិនបានបង់នៅក្នុងកាលបរិច្ឆេទរបាយការណ៍។ ពន្ធត្រូវបង់លើពន្ធប្រាក់ចំណូលក្នុងគ្រា ខុសគ្នាពីប្រាក់ចំណេញ ឬខាតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យារ ត្រូវបានគណនាដោយតាមលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្មនិងបំណុល និងមូលដ្ឋានពន្ធដែលបានរំពឹងទុកថាកើតមានឡើង ឬថយចុះនៃពន្ធលើប្រាក់ចំណេញត្រូវបង់នៅពេលអនាគត និងខាងបង់ពន្ធដែលមិនបានប្រើប្រាស់ និងឥណទានមិនបានប្រើប្រាស់។

ពន្ធពន្យារលើទ្រព្យសកម្ម និងបំណុល ត្រូវបានគណនាដោយមិនគិតអប្បហារ នៅអត្រាពន្ធដែលរំពឹងទុកថាអាចប្រើប្រាស់ទៅក្នុងរយៈពេលដែលអាចសម្រេចផ្តល់ឱ្យ ដែលអនុម័តផ្តល់ឱ្យ ឬបានអនុម័តយ៉ាងជាក់លាក់នៅកាលបរិច្ឆេទនៃរបាយការណ៍ ពិចារណាទៅលើលទ្ធផលដែលអាចកើតមានទាំងអស់នៃការពិនិត្យឡើងវិញដោយអាជ្ញាធរពន្ធដារ។

តម្លៃយោងនៃពន្ធពន្យារទ្រព្យសកម្មត្រូវបានពិនិត្យឡើងវិញ នូវរាល់កាលបរិច្ឆេទនៃរបាយការណ៍ និងកែតម្រូវជាចាំបាច់ទៅតាមការវាយតម្លៃនាពេលបច្ចុប្បន្ននៃពន្ធលើប្រាក់ចំណេញដែលត្រូវបង់នាពេលអនាគត។

## ៣.២០. ភាគីសម្ព័ន្ធញាតិ

ភាគីសម្ព័ន្ធញាតិ គឺជាបុគ្គល ឬអង្គភាពដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន។ ប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងក្រុមហ៊ុន និងភាគីសម្ព័ន្ធញាតិរបស់ខ្លួនដោយមិនគិតពីតម្លៃដែលត្រូវបានទទួលពីភាគីសម្ព័ន្ធញាតិ។

ក. រូបវន្តបុគ្គល ឬសមាជិកគ្រួសារជិតស្និទ្ធជាមួយនឹងរូបវន្តបុគ្គលដែលទាក់ទងនឹងក្រុមហ៊ុន ប្រសិនបុគ្គលនោះ៖

- (i) មានសិទ្ធិគ្រប់គ្រង ឬចូលរួមគ្រប់គ្រងរួមក្នុងក្រុមហ៊ុន
- (ii) មានឥទ្ធិពលគួរអោយកត់សម្គាល់លើក្រុមហ៊ុន ឬ
- (iii) គឺជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុនមេចុងក្រោយរបស់ក្រុមហ៊ុន ឬរបស់ក្រុមហ៊ុន

ខ. អង្គភាពដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន ប្រសិនបើមានលក្ខខណ្ឌដែលត្រូវបានអនុវត្តដូចខាងក្រោម៖

- (i) ក្រុមហ៊ុន គឺជាសមាជិកនៃសម្ព័ន្ធតែមួយ
- (ii) អង្គភាពមួយ គឺជាញាតិសម្ព័ន្ធ ឬការបណ្តាក់ទុនរួមគ្នារបស់អង្គភាពផ្សេងៗទៀត។
- (iii) អង្គភាពទាំងពីរបណ្តាក់ទុនរួមគ្នានៃភាគីទីបីដូចគ្នា។
- (iv) អង្គភាពមួយបណ្តាក់ទុនរួមគ្នាទៅលើអង្គភាពទីបី ហើយអង្គភាពផ្សេងទៀតគឺជាសហការីនៃអង្គភាពទីបី។
- (v) អង្គភាពគឺជាផែនការផលប្រយោជន៍ក្រោយការងារ សម្រាប់អត្ថប្រយោជន៍របស់និយោជិតរបស់ក្រុមហ៊ុន។
- (vi) អង្គភាពត្រូវបានគ្រប់គ្រង ឬរួមគ្នាគ្រប់គ្រងដោយបុគ្គលម្នាក់ដែលបានកំណត់នៅក្នុងចំណុច (ក) ខាងលើ។
- (vii) បុគ្គលម្នាក់ដែលត្រូវបានកំណត់នៅក្នុងចំណុច (ក) (i) ខាងលើដែលមានឥទ្ធិពលគួរអោយកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃគណៈគ្រប់គ្រងរបស់សម្ព័ន្ធញាតិនៃក្រុមហ៊ុនមេចុងក្រោយ ឬរបស់អង្គភាព។
- (viii) អង្គភាព ឬសមាជិកណាមួយនៃសម្ព័ន្ធដែលជាផ្នែកមួយ ដែលផ្តល់សេវាគ្រប់គ្រាន់សំខាន់ៗទៅឱ្យក្រុមហ៊ុន ឬទៅឱ្យក្រុមហ៊ុនមេ។

## ៣.២១. ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសម្បត្តិដែលរំលស់ត្រូវបានកំណត់ឡើងវិញនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាបញ្ជាក់ថាទ្រព្យសកម្មនោះអាចមានឱនភាពតម្លៃ។ ប្រសិនបើមានការបង្ហាញណា ដែលថាទ្រព្យសម្បត្តិនោះអាចមានឱនភាព នោះតម្លៃយោងរបស់ទ្រព្យសម្បត្តិ (ឬឯកតាបង្កើតសាច់ប្រាក់ ហៅកាត់ថា "CGU")) ដែលទ្រព្យសម្បត្តិនោះត្រូវបានបែងចែកត្រូវបានត្រួតពិនិត្យឱនភាពតម្លៃ។ ការខាតបង់លើឱនភាពតម្លៃនឹងត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬក្រុមទ្រព្យនោះ ធំជាងតម្លៃដែលអាចទារមកវិញបាន។

ចំនួនទឹកប្រាក់ដែលអាចទារមកវិញបាន គឺធំជាងតម្លៃទីផ្សារដកតម្លៃត្រូវលក់ និងតម្លៃដែលត្រូវប្រើប្រាស់របស់ទ្រព្យសកម្ម (ឬ ("CGU")។ សម្រាប់គោលបំណងនៃការវាយតម្លៃឱនភាព ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុតដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីមូលនិធិពាណិជ្ជកម្ម ដែលមានឱនភាពត្រូវបានត្រួតពិនិត្យសម្រាប់ការកត់ត្រាបញ្ច្រាស់នៃឱនភាពនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ។

## ៤. ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រងក្នុងការប្រើប្រាស់គោលការណ៍គណនេយ្យ និងការប៉ាន់ស្មាន មិនច្បាស់លាស់

ក្រុមហ៊ុនបានធ្វើការប៉ាន់ស្មានការសម្មត និងការវិនិច្ឆ័យទាក់ទងនឹងប្រតិបត្តិការនាពេលអនាគតដែលមានភាពមិនស្មើនឹងលទ្ធផលជាក់ស្តែង។ ការប៉ាន់ប្រមាណគណនេយ្យសម្មត និងការវិនិច្ឆ័យដែលអាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការទទួលស្គាល់ និងការវាស់វែងលើទ្រព្យសម្បត្តិ បំណុល ចំណូល និងចំណាយត្រូវបានសង្ខេបដូចខាងក្រោមៈ

### ក. ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

#### ចំណាយពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុនទទួលស្គាល់បំណុលសម្រាប់ការប៉ាន់ស្មានចំណាយបង់ពន្ធលើការព្យាករណ៍ថាតើពន្ធដែលត្រូវបង់តាមរយៈការគ្រប់គ្រងនៃការបកស្រាយច្បាប់ពន្ធផ្សេងនាពេលបច្ចុប្បន្ន ដែលជាកម្មវត្ថុនៃការផ្លាស់ប្តូរតាមកាលកំណត់។ ហើយការសម្រេចជាចុងក្រោយលើចំនួនចំណាយពន្ធនឹងធ្វើឡើង បន្ទាប់ពីការវាយតម្លៃដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលពន្ធចុងក្រោយចេញមកបញ្ហានេះមានភាពលម្អៀងពីចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង ភាពខុសគ្នាបែបនេះនឹងប៉ះពាល់ដល់សំវិធានធនពន្ធរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំ ដែលការសម្រេចបែបនេះនឹងត្រូវបានកើតឡើង។

#### ការទទួលស្គាល់ពន្ធពន្យារលើទ្រព្យសកម្ម

ពន្ធពន្យារទ្រព្យសកម្មអាចត្រូវបានទទួលស្គាល់ ដោយផ្អែកលើការវាយតម្លៃនៃភាពដែលអាចកើតឡើង ដែលប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតនឹងអាចមានសម្រាប់ទូទាត់លម្អៀងបណ្តោះអាសន្ន និងការខាតជាប់ពន្ធយោងពីមុនមកអាចនឹងត្រូវបានប្រើប្រាស់។ បន្ថែមពីនេះទៅទៀត ការវិនិច្ឆ័យសំខាន់ៗ គឺទាមទារអោយមានការវាយតម្លៃលើផលប៉ះពាល់នៃផ្លូវច្បាប់ ឬសេដ្ឋកិច្ច ឬភាពមិនច្បាស់លាស់ នៅក្នុងយុត្តាធិការពន្ធដារផ្សេងៗទៀត។

#### អាយុកាលនៃការប្រើប្រាស់នៃទ្រព្យសកម្មដែលអាចធ្វើរំលស់បាន

ក្រុមហ៊ុនបានពិនិត្យលើការប៉ាន់ស្មានអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសកម្ម ដែលអាចធ្វើរំលស់បាននាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗដោយផ្អែកលើការរំពឹងទុកនៃការប្រើប្រាស់របស់ទ្រព្យសកម្មទាំងនោះ។

#### ឱនភាព

នៅក្នុងការសិក្សាពីឱនភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានចំពោះទឹកប្រាក់ដែលអាចទទួលបានត្រលប់មកវិញនៃទ្រព្យសកម្មនីមួយៗ ឬឯកតាបង្កើតសាច់ប្រាក់ គឺអាស្រ័យទៅលើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត និងប្រើប្រាស់អត្រាការប្រាក់អប្បហារដើម្បីប៉ាន់ស្មាន។ ការប៉ាន់ស្មានមិនច្បាស់លាស់ដែលទាក់ទងនឹងការវិនិច្ឆ័យអំពីលទ្ធផលប្រតិបត្តិការនៅពេលអនាគត និងធ្វើការកំណត់នូវអត្រាការប្រាក់អប្បហារដែលសមស្របណាមួយ។

### ខ. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

អភិបាល គឺមិនពាក់ព័ន្ធទៅនិងការវិនិច្ឆ័យគណនេយ្យសំខាន់ៗដែលពាក់ព័ន្ធទៅនឹងចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

## ៥. និរន្តរភាពនៃដំណើរការអាជីវកម្ម

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយសន្មតថាក្រុមហ៊ុននឹងបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម។ ការខាតបង់របស់ក្រុមហ៊ុនបានកើតឡើងហើយជាលទ្ធផលបានខាតបង្គរ ចំនួន ១,៩៨១,០៦៣ ដុល្លារអាមេរិក (ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ ចំនួន ១,៩១៥,៣២៩ ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩។ កត្តាទាំងនេះបង្ហាញពីភាពមិនប្រាកដប្រជាជាសារវន្តអាចបង្កឱ្យមានការសង្ស័យអំពីសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពគឺពឹងផ្អែកទៅលើការបន្តគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ភាគហ៊ុនដើម្បីទ្រទ្រង់ប្រតិបត្តិការរបស់ខ្លួន និងបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលពួកគេត្រូវផុតកំណត់។

ម្ចាស់ភាគហ៊ុនបានធ្វើប្រតិបត្តិការជាផ្លូវការក្នុងការបន្តការគាំទ្រផ្នែកហិរញ្ញវត្ថុដែលចាំបាច់ទាំងអស់សម្រាប់ក្រុមហ៊ុនពេលដែលមានតម្រូវការកើតមានឡើង ដើម្បីឱ្យក្រុមហ៊ុនអាចបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបាន។ ការគាំទ្រផ្នែកហិរញ្ញវត្ថុទាំងនេះរួមមាន ការបន្ថែមទុនបង្វិល ការគាំទ្រដែលទាក់ទងទៅនឹងការផ្ដល់កម្ចីដល់តតីយជន និងការដោះស្រាយនូវកាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគីសម្ព័ន្ធញាតិ។

## ៦. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| ដុល្លារសហរដ្ឋអាមេរិក | ៨៣,១១៥ | ៣៣៦,២០០ | ៤៤,៩៨៤ | ១៨៣,៣១០ |
| ខ្មែររៀល | ១០,៤៧៤ | ៤២,៣៦៨ | ៤,៩៧២ | ២០,២៦១ |
| | ៩៣,៥៨៩ | ៣៧៨,៥៦៨ | ៤៩,៩៥៦ | ២០៣,៥៧១ |

## ៧. ប្រាក់បញ្ញើរ និងប្រាក់ដម្កល់តាមបទបញ្ញត្តិនៅធនាគារជាតិនៃកម្ពុជា (NBC)

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| ប្រាក់បញ្ញើរធានាដើមទុន (*) | ១៦៥,០០០ | ៦៦៧,៤២៥ | ១១៥,០០០ | ៤៦៨,៦២៥ |
| គណនីចរន្ត(**) | ៦,៧២១ | ២៧,១៨៦ | ៦,៣៧២ | ២៥,៩៦៦ |
| | ១៧១,៧២១ | ៦៩៤,៦១១ | ១២១,៣៧២ | ៤៩៤,៥៩១ |

(*) ប្រាក់បញ្ញើរធានាដើមទុនត្រូវបានរក្សាទុកនៅ ធនាគារជាតិនៃកម្ពុជាដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០០-០០៦ប្រ.ក ស្ដីពីអាជ្ញាប័ណ្ណនៃគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ដែលបានកំណត់ចំនួន ៥% នៃដើមទុន

ចុះបញ្ជី។ ប្រាក់ដម្កល់ធានាដើមទុន នឹងត្រូវបង្វិលសងវិញ នៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន ហើយគ្មានបំណុល ជាប្រាក់បញ្ញើរ។ ប្រាក់បញ្ញើរធានាដើមទុននេះទទួលបាន ការប្រាក់តាមអត្រា ០,៤៨% ទៅ ០,៧២% ក្នុងមួយឆ្នាំ។

(**) គណនីចរន្តគឺមិនទទួលបានការប្រាក់ឡើយ។

## ៨. ប្រាក់បញ្ញើរ និងប្រាក់ដម្កល់ជាមួយធនាគារផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| គណនីចរន្ត | ២១៤,២១០ | ៨៦៦,៤៧៩ | ៤២០,៦១៣ | ១,៧១៣,៩៩៨ |
| គណនីសន្សំ | ៤២ | ១៧០ | ១១,៤៨៤ | ៤៦,៧៩៧ |
| | ២១៤,២៥២ | ៨៦៦,៦៤៩ | ៤៣២,០៩៧ | ១,៧៦០,៧៩៥ |

## ៩. ឥណទាននៅឱ្យអតិថិជនៈ សុទ្ធ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| ឥណទានបុគ្គល-ដុល | ៥,៦២៣,០៦៧ | ២២,៧៤៥,៣០៦ | ៣,៨០៣,៩៥៣ | ១៥,៥០១,១០៨ |
| ការបញ្ចុះតម្លៃ | ៣៩,៣៥១ | ១៥៩,១៧៥ | ៨៧,១៨៦ | ៣៥៥,២៨៣ |
| ឥណទានបុគ្គល-ដុលសរុប | ៥,៦៦២,៤១៨ | ២២,៩០៤,៤៨១ | ៣,៨៩១,១៣៩ | ១៥,៨៥៦,៣៩១ |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | (៤០២,៧២៣) | (១,៦២៩,០១៥) | (៥៥៤,២៥៦) | (២,២៥៨,៩៩៣) |
| | ៥,២៥៩,៦៩៥ | ២១,២៧៥,៤៦៦ | ៣,៣៣៦,៨៨៣ | ១៣,៥៩៧,៧៩៨ |

បម្រែបម្រួលនៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានបង្ហាញដូចខាងក្រោមៈ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| សមតុល្យនៅដើមការិយបរិច្ឆេទ | ៥៥៤,២៥៦ | ២,២៥៨,៩៩៣ | ៣៦២,៥៨៧ | ១,៤៥៦,៨៧៤ |
| សំវិធានធនក្នុងការិយបរិច្ឆេទ | ៤១,៨៤៩ | ១៧០,៦១៨ | ១,១៣៣,៧៤៩ | ៤,៥៩៣,៩៥១ |
| ការជម្រះបញ្ជីសម្រាប់ការិយបរិច្ឆេទ | (១៩៣,៣៨២) | (៧៨៨,៤១៨) | (៩៤២,០៨០) | (៣,៨១៧,៣០៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១១,៧៧៨) | - | ២៥,០៧៦ |
| សមតុល្យនៅចុងការិយបរិច្ឆេទ | ៤០២,៧២៣ | ១,៦២៩,០១៥ | ៥៥៤,២៥៦ | ២,២៥៨,៩៩៣ |

ឥណទានដុលទៅឱ្យអតិថិជន គឺត្រូវបានវិភាគដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (សម្គាល់៣.២) | | (សម្គាល់៣.២) |
| **តាមកាលកំណត់** | | | | |
| ក្នុងរយៈពេលមួយឆ្នាំ | ១១,០៤២ | ៤៤,៦៦៥ | ១២៧,០៤០ | ៥១៧,៦៨៧ |
| ពី ១ឆ្នាំ ទៅ ៥ឆ្នាំ | ២,៣០៤,៤២០ | ៩,៣២១,៣៧៩ | ១,៤៨១,៦៤៩ | ៦,០៣៧,៧២០ |
